ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ក្របខ័ណ្ឌកម្មវិធីអប់រំ
# គ្រូបង្រៀនបឋមសិក្សា
# តាមប្រព័ន្ធ ១២+៤


នាយកដ្ឋានកិច្ចការបណ្ដុះបណ្ដាល

២០២៥

# បុព្វកថា

ក្រសួងអប់រំ យុវជន និងកីឡា បានប្ដេជ្ញាផ្ដល់ការអប់រំប្រកបដោយបរិយាបន្ន គុណភាព និងការសិក្សាពេញមួយជីវិតសម្រាប់ទាំងអស់គ្នា ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពដំណាក់កាលទី៤ ដើម្បីគាំទ្រដល់យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលកម្ពុជា។ កំណែទម្រង់វិស័យអប់រំផ្ដោតសំខាន់លើការពង្រឹងលទ្ធផលសិក្សារបស់សិស្ស អភិវឌ្ឍធនធានមនុស្សសម្រាប់បំពេញការងារប្រកបដោយការអប់រំ និងសមត្ថភាពក្នុងគោលបំណងកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។ ដើម្បីចូលរួមក្នុងការសម្រេចចក្ខុវិស័យនេះ ក្រសួងអប់រំ យុវជន និងកីឡា បានអភិវឌ្ឍផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨ និងកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាឆ្នាំ២០២៣-២០២៨ ដែលក្នុងនោះការអភិវឌ្ឍគ្រូបង្រៀនតាមរយៈកំណែទម្រង់គ្រឹះស្ថានអប់រំគ្រូបង្រៀនគឺជាអាទិភាពមួយនៃកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា។

ផែនការយុទ្ធសាស្ត្រកែទម្រង់ការអប់រំគ្រូបង្រៀននៅកម្ពុជាឆ្នាំ២០២៤-២០៣០ បានអភិវឌ្ឍផ្អែកលើផែនការសកម្មភាពគោលនយោបាយស្ដីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០ ដោយបានកំណត់យុទ្ធសាស្ត្រអាទិភាពចំនួន៤ រួមមាន (១) គន្លងសិក្សាសម្រាប់វិជ្ជាជីវៈគ្រូបង្រៀន (២) ការបង្កើនបរិមាណគ្រូបង្រៀន និងគ្រូឧទ្ទេសដែលទទួលបានការបណ្ដុះបណ្ដាលល្អ (៣) ការពង្រឹងសមត្ថភាពគ្រឹះស្ថានអប់រំគ្រូបង្រៀន និង (៤) ការជំរុញឯកទេសក្នុងការអប់រំគ្រូបង្រៀន។ ការពិនិត្យឡើងវិញក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤ ជាសកម្មភាពមួយក្នុងចំណោមសកម្មភាពនានានៃយុទ្ធសាស្ត្រអាទិភាពទី១ ក្នុងគោលបំណងត្រៀមសម្រាប់ការពង្រីកវិសាលភាពការអនុវត្តកម្មវិធីនេះនៅតាមគ្រឹះស្ថានអប់រំគ្រូបង្រៀន និងធ្វើបច្ចុប្បន្នកម្មកម្មវិធីអប់រំគ្រូបង្រៀនឱ្យស្របនឹងបរិវត្តកម្ម ការអប់រំគ្រូបង្រៀន ដើម្បីធានាថាគរុនិស្សិតទទួលបាននូវគុណសម្បទាពេញលេញឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈ គ្រូបង្រៀននៅពេលបញ្ចប់ការបណ្ដុះបណ្ដាល។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណចំពោះកម្មវិធីពង្រឹងការអប់រំគ្រូបង្រៀននៅកម្ពុជាដំណាក់កាលទី២ (STEPCam Phase II) ក្រោមមូលនិធិភាពជាដៃគូសកលសម្រាប់ការអប់រំ (GPE) ដែលបានផ្ដល់ការគាំទ្រផ្នែកបច្ចេកទេស និងថវិកា ព្រមទាំងនាយកដ្ឋានជំនាញពាក់ព័ន្ធ និងដៃគូអភិវឌ្ឍ ដែលបានចូលរួមក្នុងការពិនិត្យឡើងវិញក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ១២+៤។ ក្រសួងអប់រំ យុវជន និងកីឡានឹងជំរុញគ្រឹះស្ថានអប់រំគ្រូបង្រៀន និងអង្គភាពក្រោមឱវាទឱ្យចូលរួមអនុវត្តក្របខ័ណ្ឌនេះ និងដៃគូអភិវឌ្ឍឱ្យចូលរួមគាំទ្រ ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព នៃការអប់រំគ្រូបង្រៀននៅកម្ពុជា។៚

ថ្ងៃព្រហស្បតិ៍ ៧កើត ខែស្រាពណ៍ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២៥

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# មាតិកា


បុព្វកថា ........................................ 1
បញ្ជីតារាង ........................................ 3
ជំពូកទី១ ព័ត៌មានទូទៅ ........................................ 4
១.១. សេចក្តីផ្តើម ........................................ 4
១.២. ឈ្មោះសញ្ញាបត្រដែលទទួលបាន ........................................ 4
១.៣. គោលបំណងនៃកម្មវិធីអប់រំ ........................................ 4
១.៤. លទ្ធផលរំពឹងទុកនៃកម្មវិធីអប់រំ ........................................ 5
១.៥. អាជីពរំពឹងទុក ........................................ 6
ជំពូកទី២ សេចក្តីលម្អិតកម្មវិធីអប់រំ ........................................ 7
២.១. រចនាសម្ពន្ធកម្មវិធីអប់រំ ........................................ 7
២.២. មុខវិជ្ជាក្នុងកម្មវិធីអប់រំ ........................................ 9
២.៣. ដំណើរការកម្មវិធីអប់រំ ........................................ 11
២.៤. បំណែងចែកក្រេឌីតរួម ៤ឆ្នាំ ........................................ 15
ជំពូកទី៣ ការវាយតម្លៃ ........................................ 18
៣.១. មធ្យមភាគពិន្ទុនិទ្ទេស (GPA) ........................................ 18
៣.២. ប្រព័ន្ធពិន្ទុ និងនិទ្ទេស ........................................ 18
៣.៣. ការវាយតម្លៃមុខវិជ្ជាបង្រៀន ........................................ 19
៣.៤. ការវាយតម្លៃកម្មសិក្សាគរុកោសល្យ ........................................ 20
៣.៤. ការវាយតម្លៃលើគម្រោងស្រាវជ្រាវប្រតិបត្តិ ........................................ 22
៣.៥. ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា ........................................ 23
៣.៦. ការផ្តល់សញ្ញាបត្រ ........................................ 23
ជំពូកទី៤ ការពណ៌នាមុខវិជ្ជា ........................................ 24
៤.១. ការសិក្សាពីការអប់រំ (៣០ ក្រេឌីត) ........................................ 24
៤.២. ចំណេះដឹងលើមុខវិជ្ជា (២២ ក្រេឌីត) ........................................ 28
៤.៣. ការសិក្សាពីកម្មវិធីសិក្សា (៤៥ ក្រេឌីត) ........................................ 31
៤.៤. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត) ........................................ 36
៤.៥. ការស្រាវជ្រាវ (៦ ក្រេឌីត) ........................................ 38
ឯកសារយោង ........................................ 39

# បញ្ជីតារាង


តារាងទី 1៖ បណ្តុំមុខវិជ្ជាសិក្សា និងចំនួនក្រេឌីត....7
តារាងទី 2៖ ការអនុវត្តរូបមន្តនៃការកំណត់ក្រេឌីតសម្រាប់ការអប់រំ....8
តារាងទី 3៖ ការប្តូរចំនួនក្រេឌីតទៅចំនួនម៉ោងសិក្សាក្នុងមួយសប្តាហ៍....8
តារាងទី 4៖ មុខវិជ្ជាសិក្សានៃបណ្តុំការសិក្សាពីការអប់រំ....9
តារាងទី 5៖ មុខវិជ្ជាសិក្សានៃបណ្តុំចំណេះដឹងលើមុខវិជ្ជា....9
តារាងទី 6៖ មុខវិជ្ជាសិក្សានៃបណ្តុំការសិក្សាពីកម្មវិធីសិក្សា....10
តារាងទី 7៖ សកម្មភាពនៃបណ្តុំកម្មសិក្សាគរុកោសល្យ....11
តារាងទី 8៖ មុខវិជ្ជាសិក្សានៃបណ្តុំការស្រាវជ្រាវ....11
តារាងទី 9៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី១ ឆមាសទី១....11
តារាងទី 10៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី១ ឆមាសទី២....12
តារាងទី 11៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី២ ឆមាសទី១....12
តារាងទី 12៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី២ ឆមាសទី២....12
តារាងទី 13៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី៣ ឆមាសទី១....13
តារាងទី 14៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី៣ ឆមាសទី២....13
តារាងទី 15៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី៤ ឆមាសទី១....13
តារាងទី 16៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី៤ ឆមាសទី២....14
តារាងទី 17៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ....15
តារាងទី 18៖ ប្រព័ន្ធពិន្ទុ និងនិទ្ទេស....18
តារាងទី 19៖ ការវាយតម្លៃមុខវិជ្ជាបង្រៀន....19
តារាងទី 20៖ ការវាយតម្លៃកម្មសិក្សាគរុកោសល្យ....20
តារាងទី 21៖ ការវាយតម្លៃគម្រោងស្រាវជ្រាវប្រតិបត្តិ....22

# ជំពូកទី១
# ព័ត៌មានទូទៅ

## ១.១. សេចក្តីផ្តើម

ការអប់រំនៅសតវត្សរ៍ទី២១ ក្នុងបរិបទនៃការរីកចម្រើនយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យាឌីជីថល និងតម្រូវការនៃសង្គមពុទ្ធិ ទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់លើគុណភាពអប់រំ ដោយពឹងផ្អែកខ្លាំងលើគ្រូបង្រៀនប្រកបដោយគុណសម្បទាពេញលេញ និងមានវិជ្ជាជីវៈខ្ពស់ ដែលជាធនធានពុំអាចខ្វះបានក្នុងការកសាងមូលធនមនុស្ស ដើម្បីចូលរួមចំណែកក្នុងការកសាងសង្គមជាតិ។ ដូច្នេះការអប់រំគ្រូបង្រៀនឱ្យទទួលបាននូវវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាពេញលេញស្របតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ជាការចាំបាច់សម្រាប់សង្គមកម្ពុជា។

ការអប់រំបឋមសិក្សាជាមូលដ្ឋានគ្រឹះដ៏សំខាន់សម្រាប់ការសិក្សាពេញមួយជីវិត និងការអភិវឌ្ឍផ្ទាល់ខ្លួន ដែលធ្វើឱ្យតួនាទីរបស់គ្រូបង្រៀននៅក្នុងដំណាក់កាលនេះកាន់តែមានសារៈសំខាន់។ ដូច្នេះ ការអប់រំគ្រូបង្រៀនបឋមសិក្សាទាមទារឱ្យមានក្របខ័ណ្ឌកម្មវិធីអប់រំដ៏រឹងមាំ ទូលំទូលាយ និងឆ្លើយតបនឹងគោលបំណងនៃការអប់រំ។ ក្របខ័ណ្ឌនេះត្រូវបានរៀបចំឡើងដើម្បីផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង ជំនាញ និងគុណតម្លៃដែលចាំបាច់ដើម្បីក្លាយជាគ្រូបង្រៀនប្រកបដោយគុណសម្បទាពេញលេញ ដែលអាចជំរុញបរិយាកាសសិក្សាប្រកបដោយការគាំទ្រ និងបរិយាបន្ននៅកម្រិតសាលារៀន។

ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤ នេះ ត្រូវបានអភិវឌ្ឍឡើងដោយផ្អែកលើស្តង់ដាកម្មវិធីអប់រំមួយចំនួនទាំងក្នុងប្រទេស និងក្នុងតំបន់រួមមាន កម្មវិធីអប់រំគ្រូបង្រៀននៅវិទ្យាស្ថានជាតិអប់រំរបស់ប្រទេសសិង្ហបុរី (NTU/NIE, 2017) ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនមត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិឆ្នាំ២០២៣ កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀនបឋមសិក្សានិងអនុវិទ្យាល័យតាមប្រព័ន្ធ ១២+២ និងកម្មវិធីសិក្សាចំណេះទូទៅនិងការអប់រំបច្ចេកទេសរបស់ក្រសួងអប់រំ យុវជន និងកីឡា (ក្រ.អយក ឆ្នាំ២០១៦)។

## ១.២. ឈ្មោះសញ្ញាបត្រដែលទទួលបាន

ភាសាខ្មែរ៖ **បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនបឋមសិក្សា**

ភាសាអង់គ្លេស៖ **Bachelor of Education in Teaching (Primary School)**

## ១.៣. គោលបំណងនៃកម្មវិធីអប់រំ

កម្មវិធីអប់រំនេះ ត្រូវបានកំណត់ដោយរួមបញ្ចូលគ្នារវាងគុណភាពអប់រំកម្រិតបរិញ្ញាបត្រ និងកម្រិតចំណេះទូទៅនៅក្នុងប្រព័ន្ធអប់រំ ដើម្បីធានាថានៅពេលបញ្ចប់ការអប់រំ គរុនិស្សិតទទួលបាននូវគុណសម្បទាពេញលេញរួមមាន វិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដើម្បីបំពេញការងារបានល្អប្រសើរក្នុងវិស័យអប់រំ ឆ្លើយតបទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ និងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន។ កម្មវិធីអប់រំនេះនឹងផ្តល់ឱ្យគរុនិស្សិតនូវ៖

- PEO1: ចំណេះដឹងច្បាស់លាស់លើមុខវិជ្ជាបង្រៀន ចិត្ត-គរុកោសល្យ វិធីសាស្ត្របង្រៀន និងការវាយតម្លៃការសិក្សាសម្បូរបែបឆ្លើយតបទៅនឹងបរិបទនៃការវិវត្តសង្គម

- PEO2: សមត្ថភាពអនុវត្ត និងចែករំលែកចំណេះដឹង ចិត្ត-គរុកោសល្យ វិធីសាស្ត្របង្រៀនដែលមានប្រសិទ្ធភាព និងការវាយតម្លៃការសិក្សា ដើម្បីលើកកម្ពស់ការរៀនសកម្មរបស់សិស្សប្រកបដោយគុណភាព និងប្រសិទ្ធភាព
- PEO3: សមត្ថភាពផ្នែកបច្ចេកវិទ្យា ភាសាបរទេស និងបំណិនជីវិត គាំទ្រក្នុងការរៀបចំការបង្រៀន និងរៀន ឆ្លើយតបនឹងបំណិនសតវត្សរ៍ទី២១ និងការអប់រំឌីជីថល ផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅ
- PEO4: ចំណេះដឹង និងជំនាញស្រាវជ្រាវអប់រំ ដើម្បីបង្កើនចំណេះដឹង ជំនាញ និងបទពិសោធសម្រាប់អភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ និងបណ្តុះនូវវប្បធម៌នៃការសិក្សាពេញមួយជីវិត
- PEO5: ក្រមសីលធម៌វិជ្ជាជីវៈ ទំនាក់ទំនងអន្តរបុគ្គល ភាពជាអ្នកដឹកនាំ និងភាពជាពលរដ្ឋសាកល។

## ១.៤. លទ្ធផលរំពឹងទុកនៃកម្មវិធីអប់រំ

បន្ទាប់ពីបានសិក្សាក្នុងកម្មវិធីអប់រំគ្រូបង្រៀនរយៈពេល ៤ឆ្នាំសិក្សា គរុនិស្សិតនឹងមានសមត្ថភាពអប់រំដូចខាងក្រោម៖

### ក. ចំណេះដឹង

- PLO1: កំណត់បានពីតម្រូវការសិក្សា សមត្ថភាពសិក្សា ប្រវត្តិសិក្សា ស្ថានភាពគ្រួសារ និងកត្តាផ្សេងៗ ដែលមានឥទ្ធិពលដល់ការសិក្សារបស់សិស្សនៅបឋមសិក្សា
- PLO2: រៀបរាប់ពីខ្លឹមសារមុខវិជ្ជា វិធីសាស្ត្របង្រៀន និងការវាយតម្លៃការសិក្សាឆ្លើយតបនឹងកម្មវិធីសិក្សានៅបឋមសិក្សា
- PLO3: ពន្យល់ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន កម្មវិធីសិក្សា គោលនយោបាយអប់រំជាតិ គោលដៅអប់រំជាតិនិងអន្តរជាតិ និងស្តង់ដាពាក់ព័ន្ធទៅនឹងការអប់រំបឋមសិក្សា

### ខ. ជំនាញការគិត (ចំណេះដឹងវិភាគ)

- PLO4: រៀបចំកិច្ចតែងការបង្រៀន សម្ភារឧបទេស និងឧបករណ៍វាយតម្លៃការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព
- PLO5: ដោះស្រាយបញ្ហាប្រឈមដែលកើតមានឡើងក្នុងថ្នាក់រៀនផ្អែកលើស្ថានភាពជាក់ស្តែង និង/ឬ លទ្ធផលស្រាវជ្រាវ
- PLO6: វិភាគកម្មវិធីសិក្សា ការអនុវត្តវិធីសាស្ត្របង្រៀន និងការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយប្រសិទ្ធភាព និងភាពបត់បែន

### គ. ជំនាញទំនាក់ទំនងអន្តរបុគ្គល និងទំនួលខុសត្រូវ

- PLO7: បង្កើតទំនាក់ទំនងល្អជាមួយសិស្ស អ្នកអាណាព្យាបាល សហការី និងសហគមន៍ប្រកបដោយប្រសិទ្ធភាព
- PLO8: ប្រើប្រាស់ភាសាបរទេសសម្រាប់ទំនាក់ទំនងតាមរយៈសំណេរ និងផ្ទាល់មាត់
- PLO9: បង្កើតបរិយាកាសសិក្សាបែបវិជ្ជមាន បរិយាបន្ន និងសុខុមាលភាព
- PLO10: អនុវត្តការបង្រៀនប្រកបដោយស្មារតីទទួលខុសត្រូវ យកចិត្តទុកដាក់ចំពោះការសិក្សារបស់សិស្សឆ្លើយតបនឹងការប្រតិបត្តិវិជ្ជាជីវៈគ្រូបង្រៀន

### ឃ. ជំនាញទំនាក់ទំនង បច្ចេកវិទ្យា និងលេខនព្វន្ត

- PLO11: ប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ និងបញ្ញាសិប្បនិម្មិត សម្រាប់គាំទ្រការបង្រៀន និងរៀនប្រកបដោយវិជ្ជាជីវៈ
- PLO12: វិភាគទិន្នន័យ លទ្ធផលនៃការវាយតម្លៃ ការស្រាវជ្រាវប្រតិបត្តិ និងស្ថិតិអប់រំ

### ង. ជំនាញចិត្តចលនា

- PLO13: ប្រើប្រាស់កិច្ចតែងការបង្រៀន សម្ភារឧបទេស និងឧបករណ៍វាយតម្លៃដែលសមស្រប និងប្រកបដោយប្រសិទ្ធភាព
- PLO14: គ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព និងភាពបត់បែនស្របតាមសមត្ថភាពរបស់សិស្ស
- PLO15: ធ្វើបទបង្ហាញលទ្ធផលស្រាវជ្រាវប្រតិបត្តិប្រកបដោយប្រសិទ្ធភាព។

## ១.៥. អាជីពរំពឹងទុក

គរុនិស្សិតនឹងក្លាយជាគ្រូបង្រៀនដែលមានវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទា សមស្របឆ្លើយតបនឹងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន និងមានការទទួលស្គាល់ពីសង្គម។

# ជំពូកទី២
## សេចក្តីលម្អិតកម្មវិធីអប់រំ

## ២.១. រចនាសម្ពន្ធកម្មវិធីអប់រំ

### ២.១.១. បណ្តុំមុខវិជ្ជាសិក្សា

កម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ១២+៤ នឹងផ្តល់នូវប្រធានបទសិក្សា និងសកម្មភាពជាច្រើនដែលបែងចែកជា៥បណ្តុំមុខវិជ្ជាសិក្សា៖

- ការសិក្សាពីការអប់រំ
- ចំណេះដឹងលើមុខវិជ្ជា
- ការសិក្សាពីកម្មវិធីសិក្សា
- កម្មសិក្សាគរុកោសល្យ
- ការស្រាវជ្រាវ

*តារាងទី 1៖ បណ្តុំមុខវិជ្ជាសិក្សា និងចំនួនក្រេឌីត*

| ល.រ | បណ្តុំមុខវិជ្ជាសិក្សា | ចំនួនក្រេឌីត | ភាគរយ (%) |
|---|---|---|---|
| ១ | ការសិក្សាពីការអប់រំ (Education Studies) | ៣០ | ២៤.០០ |
| ២ | ចំណេះដឹងលើមុខវិជ្ជា (Subject Knowledge) | ២២ | ១៧.៦០ |
| ៣ | ការសិក្សាពីកម្មវិធីសិក្សា (Curriculum Studies) | ៤៥ | ៣៦.០០ |
| ៤ | កម្មសិក្សាគរុកោសល្យ (Practicum) | ២២ | ១៧.៦០ |
| ៥ | ការស្រាវជ្រាវ (Research) | ៦ | ៤.៨០ |
| **សរុប** | | **១២៥** | **១០០** |

កម្មវិធីអប់រំគ្រូបង្រៀននេះ មានរយៈពេល ៤ឆ្នាំសិក្សាស្មើនឹង ១២៥ក្រេឌីត។ គ្រឹះស្ថានអប់រំគ្រូបង្រៀនអាចរៀបចំជាសកម្មភាពក្រៅកម្មវិធីអប់រំតាមការចាំបាច់ដោយមិនផ្តល់ក្រេឌីត។

### ២.១.២. ការកំណត់ក្រេឌីតនៃការអប់រំ

ចំនួនក្រេឌីតនៃកម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤ ត្រូវបែងចែកជាបីប្រភេទដូចខាងក្រោម៖

- **ការសិក្សាទ្រឹស្តី៖** មួយក្រេឌីតនៃការអប់រំទ្រឹស្តី ជាការបង្រៀននៅក្នុងថ្នាក់រៀន រយៈពេលមួយម៉ោងក្នុងមួយសប្តាហ៍ ឬមានចំនួនមិនតិចជាង ១៥ម៉ោងក្នុងមួយឆមាស
- **ការសិក្សាប្រតិបត្តិ៖** មួយក្រេឌីតនៃការអប់រំប្រតិបត្តិ ជាការហ្វឹកហាត់ ឬការធ្វើពិសោធនៅក្នុងទីពិសោធ មានរយៈពេលយ៉ាងតិច ២ម៉ោងក្នុងមួយសប្តាហ៍ ឬមានចំនួនមិនតិចជាង ៣០ម៉ោង ក្នុងមួយឆមាស

- **ការអនុវត្តជាក់ស្តែង (កម្មសិក្សាគរុកោសល្យ)៖** មួយក្រេឌីតនៃការអប់រំអនុវត្តជាក់ស្តែងជាការអប់រំនៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងឯកជន ឬកន្លែងអនុវត្តជាក់ស្តែងផ្សេងៗទៀតដែលមានរយៈពេលយ៉ាងតិច ០៣ម៉ោងក្នុងមួយសប្តាហ៍ ឬមានចំនួនមិនតិចជាង ៤៥ម៉ោងក្នុងមួយឆមាស។

សម្រាប់ការអនុវត្តរូបមន្តនៃការកំណត់ក្រេឌីតសម្រាប់ការអប់រំ ត្រូវអនុវត្តតាមគំរូរូបមន្តដូចក្នុង តារាងទី2។

***តារាងទី 2៖ ការអនុវត្តរូបមន្តនៃការកំណត់ក្រេឌីតសម្រាប់ការអប់រំ***

| | **(លេខកូដមុខវិជ្ជា)** | **ឈ្មោះមុខវិជ្ជា** | **ចំនួនក្រេឌីត (X-Y-Z)** |
|---|---|---|---|
| ឧទាហរណ៍ | 101203 | ចិត្តវិទ្យាអប់រំ | ៣ (៣-០-៦) |
| | 101405 | ទស្សនវិជ្ជាអប់រំ | ២ (២-០-៤) |
| ចំនួនក្រេឌីត | ចំនួន១ ២ ឬ៣ក្រេឌីត<br>X ចំនួនម៉ោងសិក្សាទ្រឹស្តី<br>Y ចំនួនម៉ោងសិក្សាប្រតិបត្តិ ឬចំនួនម៉ោងកម្មសិក្សាគរុកោសល្យ (សម្រាប់មុខវិជ្ជាកម្មសិក្សាគរុកោសល្យ)<br>Z ចំនួនម៉ោងស្វ័យសិក្សា | | |

***តារាងទី 3៖ ការប្តូរចំនួនក្រេឌីតទៅចំនួនម៉ោងសិក្សាក្នុងមួយសប្តាហ៍***

| **ការប្តូរក្រេឌីតទៅជាចំនួនម៉ោងសិក្សា** | | |
|---|---|---|
| | ចំនួនក្រេឌីត | ចំនួនម៉ោង |
| ការសិក្សាទ្រឹស្តី | ១ក្រេឌីត | ១ម៉ោង/សប្តាហ៍ |
| ការសិក្សាប្រតិបត្តិ | ១ក្រេឌីត | ២ម៉ោង/សប្តាហ៍ |
| កម្មសិក្សាគរុកោសល្យ | ១ក្រេឌីត | ៣ម៉ោង/សប្តាហ៍ |
| **ការប្តូរចំនួនម៉ោងការសិក្សាទៅជាចំនួនម៉ោងស្វ័យសិក្សា** | | |
| | ចំនួនម៉ោង | ចំនួនម៉ោងស្វ័យសិក្សា |
| ការសិក្សាទ្រឹស្តី | ១ម៉ោង/សប្តាហ៍ | ២ម៉ោង/សប្តាហ៍ |
| ការសិក្សាប្រតិបត្តិ ឬកម្មសិក្សា | ១ម៉ោង/សប្តាហ៍ | កន្លះម៉ោង/សប្តាហ៍ |

ឧទាហរណ៍ទី១៖ មុខវិជ្ជា ក ផ្តោតលើការសិក្សាទ្រឹស្តីតែម្យ៉ាងគត់ចំនួន៣ក្រេឌីត ត្រូវសរសេរ ៣ (៣-០-៦)។

ឧទាហរណ៍ទី២៖ មុខវិជ្ជា ខ ចំនួន៣ក្រេឌីត សិក្សាទ្រឹស្តីចំនួន២ក្រេឌីត និងការសិក្សាប្រតិបត្តិចំនួន ១ក្រេឌីត ត្រូវសរសេរ ៣ (២-២-៥)។

ឧទាហរណ៍ទី៣៖ មុខវិជ្ជា គ សរុបចំនួន៣ក្រេឌីត ផ្តោតលើការសិក្សាប្រតិបត្តិតែម្យ៉ាងគត់ ត្រូវសរសេរ ៣ក្រេឌីត ៣ (០-៦-៣)។

ដើម្បីបញ្ចប់កម្មវិធីអប់រំនេះ គរុនិស្សិតត្រូវសិក្សាលើបណ្តុំមុខវិជ្ជាសិក្សាចំនួន៥ រួមមាន ការសិក្សាពីការអប់រំ (៣០ក្រេឌីត) ចំណេះដឹងលើមុខវិជ្ជា (២២ក្រេឌីត) ការសិក្សាពីកម្មវិធីសិក្សា (៤៥ក្រេឌីត) កម្មសិក្សាគរុកោសល្យ (២២ក្រេឌីត) និងការស្រាវជ្រាវ (៦ក្រេឌីត)។

#### ២.១.៣. រយៈពេលនៃការអប់រំ

កម្មវិធីអប់រំនេះ តម្រូវឱ្យគរុនិស្សិតសិក្សារយៈពេល៤ឆ្នាំ ដើម្បីទទួលបានបរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនបឋមសិក្សា។ គរុនិស្សិតទាំងអស់អាចទទួលបានសញ្ញាបត្រកម្រិតនេះអាស្រ័យលើលទ្ធផលសិក្សារបស់គរុនិស្សិតម្នាក់ៗ។ គរុនិស្សិតមិនត្រូវបានអនុញ្ញាតឱ្យសិក្សាលើសពីរយៈពេល៦ឆ្នាំឡើយ ដែលគិតចាប់ពីថ្ងៃចុះឈ្មោះចូលរៀន។ ឆ្នាំសិក្សានីមួយៗត្រូវបានបែងចែកជា ២ឆមាស ក្នុងនោះមួយឆមាសមានចំនួន យ៉ាងតិច ១៥សប្តាហ៍។

## ២.២. មុខវិជ្ជាក្នុងកម្មវិធីអប់រំ

#### ២.២.១. ការពីសិក្សាពីការអប់រំ (Education Studies)

*តារាងទី 4៖ មុខវិជ្ជាសិក្សានៃបណ្តុំការសិក្សាពីការអប់រំ*

| | | |
|---|---|---|
| 1. | ចិត្តវិទ្យាអប់រំ៖ ទ្រឹស្តី និងការអនុវត្តសម្រាប់ការរៀននិងបង្រៀន (១ និង ២) | ៦ (៦-០-១២) |
| 2. | ការវាយតម្លៃការសិក្សា | ៣ (៣-០-៦) |
| 3. | ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ | ២ (២-០-៤) |
| 4. | មូលដ្ឋានគ្រឹះនៃការអប់រំ | ៣ (៣-០-៦) |
| 5. | គរុកោសល្យ និងការបង្រៀន | ៣ (៣-០-៦) |
| 6. | អប់រំសុខភាព និងការអប់រំកាយនិងកីឡា | ៣ (២-២-៥) |
| 7. | មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត | ២ (២-០-៤) |
| 8. | ការប្រើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន | ៦ (៤-៤-១០) |
| 9. | បំណិនជីវិត ការប្រែប្រួលអាកាសធាតុ បណ្ណាល័យ និងអក្ខរសាស្ត្រអំណាន | ២ (១-២-៣) |
| **សរុប** | | **៣០ ក្រេឌីត** |

#### ២.២.២.ចំណេះដឹងលើមុខវិជ្ជា (Subject Knowledge)

*តារាងទី 5៖ មុខវិជ្ជាសិក្សានៃបណ្តុំចំណេះដឹងលើមុខវិជ្ជា*

| | | | |
|---|---|---|---|
| 1. | ភាសាខ្មែរ | មូលដ្ឋានគ្រឹះអក្សរសាស្ត្រខ្មែរ (វេយ្យាករណ៍ និងសំណេរតែងសេចក្តី) | ៣ (២-២-៥) |
| | | មូលដ្ឋានគ្រឹះអក្សរសាស្ត្រខ្មែរ (អក្សរសិល្ប៍) | ៣ (២-២-៥) |
| 2. | គណិតវិទ្យា | មូលដ្ឋានគ្រឹះគណិតវិទ្យាបឋមសិក្សា | ៣ (៣-០-៦) |
| | | ការពង្រឹងចំណេះដឹងមុខវិជ្ជាគណិតវិទ្យា | ៣ (៣-០-៦) |
| 3. | វិទ្យាសាស្ត្រ | មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សា (រូប គីមី ជីវៈ) | ៣ (៣-០-៦) |

| | | | |
|---|---|---|---|
| | | មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សា(ផែនដី ការអប់រំបរិស្ថាន) | ២ (២-០-៤) |
| 4. | សិក្សាសង្គម | មូលដ្ឋានគ្រឹះសិក្សាសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា) | ៣ (៣-០-៦) |
| | | មូលដ្ឋានគ្រឹះមុខវិជ្ជាសិក្សាសង្គម (សីលធម៌ ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) | ២ (១-២-៣) |
| **សរុប** | | | **២២ ក្រេឌីត** |

### ២.២.៣. ការសិក្សាពីកម្មវិធីសិក្សា (Curriculum Studies)

***តារាងទី 6៖ មុខវិជ្ជាសិក្សានៃបណ្តុំការសិក្សាពីកម្មវិធីសិក្សា***

| | | | |
|---|---|---|---|
| 1. | ភាសាខ្មែរ | វិធីបង្រៀនភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី១ | ៣ (២-២-៥) |
| | | វិធីបង្រៀនភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី២ និង៣ | ២ (១-២-៣) |
| | | វិធីបង្រៀនភាសាខ្មែរថ្នាក់ទី៤ ដល់ ៦ | ៣ (២-២-៥) |
| | | ការវាយតម្លៃការសិក្សាភាសាខ្មែរនៅកម្រិតបឋមសិក្សា | ៣ (២-២-៥) |
| 2. | គណិតវិទ្យា | ការបង្រៀន និងរៀនគណិតវិទ្យា I | ៣ (២-២-៥) |
| | | ការបង្រៀន និងរៀនគណិតវិទ្យា II | ៣ (២-២-៥) |
| | | ការបង្រៀន និងរៀនគណិតវិទ្យា III | ៣ (២-២-៥) |
| | | ការវាយតម្លៃការសិក្សាគណិតវិទ្យានៅបឋមសិក្សា | ២ (១-២-៣) |
| 3. | វិទ្យាសាស្ត្រ | ការសិក្សាកម្មវិធីសិក្សា និងការអនុវត្តវិទ្យាសាស្ត្រសម្រាប់បឋមសិក្សា | ៣ (៣-០-៦) |
| | | គរុកោសល្យសម្រាប់បឋមសិក្សា និងការវាយតម្លៃលើមុខវិជ្ជាវិទ្យាសាស្ត្របឋមសិក្សា | ៣ (៣-០-៦) |
| | | នវានុវត្តន៍ក្នុងការរៀបចំ និងអនុវត្តគម្រោងសម្រាប់វិទ្យាសាស្ត្របឋមសិក្សា | ៣ (៣-០-៦) |
| 4. | សិក្សាសង្គម | ការបង្រៀន និងរៀនសិក្សាសង្គមនៅបឋមសិក្សា | ៣ (២-២-៥) |
| | | វិធីសាស្ត្របង្រៀន និងការវាយតម្លៃមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា | ៣ (២-២-៥) |
| | | បញ្ញត្តិ និងការអប់រំសិល្បៈ(គំនូរ-ហត្ថកម្ម) | ២ (១-២-៣) |
| | | បញ្ញត្តិ និងការអប់រំសិល្បៈ(តន្ត្រី-របាំ) | ៣ (២-២-៥) |
| 5. | ភាសាអង់គ្លេស | វិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា | ៣ (២-២-៥) |
| **សរុប** | | | **៤៥ ក្រេឌីត** |

#### ២.២.៤. កម្មសិក្សាគរុកោសល្យ ( Practicum )

*តារាងទី 7៖ សកម្មភាពនៃបណ្តុំកម្មសិក្សាគរុកោសល្យ*

| | | |
|---|---|---|
| 1. | ការដកស្រង់បទពិសោធនៅសាលារៀន | ២ ក្រេឌីត |
| 2. | ភាពជាអ្នកជំនួយការបង្រៀន | ៥ ក្រេឌីត |
| 3. | ការអនុវត្តការបង្រៀន ១ | ៥ ក្រេឌីត |
| 4. | ការអនុវត្តការបង្រៀន ២ | ១០ ក្រេឌីត |
| **សរុប** | | **២២ ក្រេឌីត** |

#### ២.២.៥. ការស្រាវជ្រាវ ( Research )

*តារាងទី 8៖ មុខវិជ្ជាសិក្សានៃបណ្តុំការស្រាវជ្រាវ*

| | | |
|---|---|---|
| 1. | ការស្រាវជ្រាវអប់រំ ( Educational Research ) | ៣ ( ៣-០-៦ ) |
| 2. | គម្រោងស្រាវជ្រាវប្រតិបត្តិ ( Action Research Project ) | ៣ ក្រេឌីត |
| **សរុប** | | **៦ ក្រេឌីត** |

### ២.៣. ដំណើរការកម្មវិធីអប់រំ

រចនាសម្ពន្ធកម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាតាមប្រព័ន្ធ ១២+៤ នៅគ្រឹះស្ថានអប់រំគ្រូបង្រៀនត្រូវបានបង្ហាញក្នុងតារាងខាងក្រោម៖

*តារាងទី 9៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី១ ឆមាសទី១*

| **លេខកូដ** | **មុខវិជ្ជា** | **ចំនួនក្រេឌីត** | **បណ្តុំមុខវិជ្ជាសិក្សា** |
|---|---|---|---|
| | មូលដ្ឋានគ្រឹះនៃការអប់រំ | ៣ ( ៣-០-៦ ) | ការសិក្សាពីការអប់រំ |
| | ការប្រើបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្រាប់ការបង្រៀននិងរៀន | ៣ ( ២-២-៥ ) | ការសិក្សាពីការអប់រំ |
| | មូលដ្ឋានគ្រឹះអក្សរសាស្ត្រខ្មែរ (វេយ្យាករណ៍ និងសំណេរតែងសេចក្តី ) | ៣ ( ២-២-៥ ) | ចំណេះដឹងលើមុខវិជ្ជា |
| | មូលដ្ឋានគ្រឹះគណិតវិទ្យានៅបឋមសិក្សា | ៣ ( ៣-០-៦ ) | ចំណេះដឹងលើមុខវិជ្ជា |
| | មូលដ្ឋានគ្រឹះសិក្សាសង្គម( ប្រវត្តិវិទ្យាភូមិវិទ្យា ) | ៣ ( ៣-០-៦ ) | ចំណេះដឹងលើមុខវិជ្ជា |
| | ការបង្រៀន និងរៀនគណិតវិទ្យា I | ៣ ( ២-២-៥ ) | ការសិក្សាពីកម្មវិធីសិក្សា |
| **សរុប** | | **១៨ ក្រេឌីត** | |

*តារាងទី 10៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី១ ឆមាសទី២*

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | បណ្តុំមុខវិជ្ជាសិក្សា |
|---|---|---|---|
| | ចិត្តវិទ្យាអប់រំ៖ ទ្រឹស្តី និងការអនុវត្ត សម្រាប់ការរៀននិងបង្រៀន (១ និង ២) | ៣ (៣-០-៦) | ការសិក្សាពីការអប់រំ |
| | អប់រំសុខភាព និងអប់រំកាយនិងកីឡា | ៣ (២-២-៥) | ការសិក្សាពីការអប់រំ |
| | បំណិនជីវិត ការប្រែប្រួលអាកាសធាតុ បណ្ណាល័យ និងអក្ខរសាស្ត្រអំណាន | ២ (១-២-៣) | ការសិក្សាពីការអប់រំ |
| | មូលដ្ឋានគ្រឹះអក្សរសាស្ត្រខ្មែរ (អក្សរសិល្ប៍ និងតែងសេចក្តី) | ៣ (២-២-៥) | ចំណេះដឹងលើមុខវិជ្ជា |
| | មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សា (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា) | ៣ (៣-០-៦) | ចំណេះដឹងលើមុខវិជ្ជា |
| | ការដកស្រង់បទពិសោធនៅសាលារៀន | ២ | កម្មសិក្សាគរុកោសល្យ |
| **សរុប** | | **១៦** | |

*តារាងទី 11៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី២ ឆមាសទី១*

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | បណ្តុំមុខវិជ្ជាសិក្សា |
|---|---|---|---|
| | ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ | ២ (២-០-៤) | ការសិក្សាពីការអប់រំ |
| | គរុកោសល្យ និងការបង្រៀន | ៣ (៣-០-៦) | ការសិក្សាពីការអប់រំ |
| | មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត | ២ (២-០-៤) | ការសិក្សាពីការអប់រំ |
| | វិធីបង្រៀនភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី១ | ៣ (២ -២-៥) | ការសិក្សាពីកម្មវិធីសិក្សា |
| | ការបង្រៀន និងរៀនគណិតវិទ្យា II | ៣ (២-២-៥) | ការសិក្សាពីកម្មវិធីសិក្សា |
| | ការសិក្សាកម្មវិធីសិក្សា និងការអនុវត្តវិទ្យាសាស្ត្រសម្រាប់បឋមសិក្សា | ៣ (៣-០-៦) | ការសិក្សាពីកម្មវិធីសិក្សា |
| | ការបង្រៀន និងរៀនសិក្សាសង្គមនៅបឋមសិក្សា | ៣ (២-២-៥) | ការសិក្សាពីកម្មវិធីសិក្សា |
| **សរុប** | | **១៩** | |

*តារាងទី 12៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី២ ឆមាសទី២*

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | បណ្តុំមុខវិជ្ជាសិក្សា |
|---|---|---|---|
| | ការវាយតម្លៃការសិក្សា | ៣ (៣-០-៦) | ការសិក្សាពីការអប់រំ |
| | ការប្រើបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន | ៣ (២-២-៥) | ការសិក្សាពីការអប់រំ |
| | មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សា (ផែនដីវិទ្យា ការអប់រំបរិស្ថាន) | ២ (២-០-៤) | ចំណេះដឹងលើមុខវិជ្ជា |

| | | | |
|---|---|---|---|
| | មូលដ្ឋានគ្រឹះមុខវិជ្ជាសិក្សាសង្គម (សីលធម៌ ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) | ២ (១-២-៣) | ចំណេះដឹងលើមុខវិជ្ជា |
| | វិធីបង្រៀនភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី២ និង៣ | ២ (១-២-៣) | ការសិក្សាពីកម្មវិធីសិក្សា |
| | បញ្ញត្តិ និងការអប់រំសិល្បៈ(គំនូរ-ហត្ថកម្ម) | ២ (១-២-៣) | ការសិក្សាពីកម្មវិធីសិក្សា |
| | ភាពជាអ្នកជំនួយការបង្រៀន | ៥ | កម្មសិក្សាគរុកោសល្យ |
| **សរុប** | | **១៩** | |

*តារាងទី 13៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី៣ ឆមាសទី១*

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | បណ្តុំមុខវិជ្ជាសិក្សា |
|---|---|---|---|
| | ការពង្រឹងចំណេះដឹងគណិតវិទ្យា | ៣ (៣-០-៦) | ចំណេះដឹងលើមុខវិជ្ជា |
| | ការបង្រៀននិងរៀនគណិតវិទ្យា III | ៣ (២-២-៥) | ការសិក្សាកម្មវិធីសិក្សា |
| | គរុកោសល្យសម្រាប់បឋមសិក្សា និងការវាយតម្លៃលើមុខវិជ្ជាវិទ្យាសាស្ត្រនៅបឋមសិក្សា | ៣ (៣-០-៦) | ការសិក្សាកម្មវិធីសិក្សា |
| | វិធីសាស្ត្របង្រៀន និងការវាយតម្លៃមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា | ៣ (២-២-៥) | ការសិក្សាកម្មវិធីសិក្សា |
| | វិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា | ៣ (២-២-៥) | ការសិក្សាកម្មវិធីសិក្សា |
| | ការស្រាវជ្រាវអប់រំ | ៣ (៣-០-៦) | ការស្រាវជ្រាវ |
| **សរុប** | | **១៨** | |

*តារាងទី 14៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី៣ ឆមាសទី២*

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | បណ្តុំមុខវិជ្ជាសិក្សា |
|---|---|---|---|
| | ចិត្តវិទ្យាអប់រំ៖ ទ្រឹស្តី និងការអនុវត្តសម្រាប់ការរៀននិងបង្រៀន (១ និង ២) | ៣ (៣-០-៦) | ការសិក្សាពីការអប់រំ |
| | វិធីបង្រៀនភាសាខ្មែរថ្នាក់ទី៤ ដល់ ៦ | ៣ (២-២-៥) | ការសិក្សាពីកម្មវិធីសិក្សា |
| | បញ្ញត្តិ និងការអប់រំសិល្បៈ(តន្ត្រី-របាំ) | ៣ (២-២-៥) | ការសិក្សាពីកម្មវិធីសិក្សា |
| | ការអនុវត្តការបង្រៀន ១ | ៥ | កម្មសិក្សាគរុកោសល្យ |
| **សរុប** | | **១៤** | |

*តារាងទី 15៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី៤ ឆមាសទី១*

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | បណ្តុំមុខវិជ្ជាសិក្សា |
|---|---|---|---|
| | ការវាយតម្លៃការសិក្សាគណិតវិទ្យានៅបឋមសិក្សា | ២ (១-២-៣) | ការសិក្សាពីកម្មវិធីសិក្សា |
| | នវានុវត្តន៍ក្នុងការរៀបចំ និងអនុវត្តគម្រោងសម្រាប់វិទ្យាសាស្ត្រនៅបឋមសិក្សា | ៣ (៣-០-៦) | ការសិក្សាពីកម្មវិធីសិក្សា |
| **សរុប** | | **៥** | |

*តារាងទី 16៖ មុខវិជ្ជាដែលត្រូវសិក្សានៅឆ្នាំទី៤ ឆមាសទី២*

| លេខកូដ | មុខវិជ្ជា | ចំនួនក្រេឌីត | បណ្ដុំមុខវិជ្ជាសិក្សា |
|---|---|---|---|
| | ការវាយតម្លៃការសិក្សាភាសាខ្មែរកម្រិតបឋមសិក្សា | ៣ (២-២-៥) | ការសិក្សាពីកម្មវិធីសិក្សា |
| | ការអនុវត្តការបង្រៀន ២ | ១០ | កម្មសិក្សាគរុកោសល្យ |
| | គម្រោងស្រាវជ្រាវប្រតិបត្តិ | ៣ | ការស្រាវជ្រាវ |
| **សរុប** | | **១៦** | |

## ២.៤. បំណែងចែកក្រេឌីតរួម ៤ឆ្នាំ

*តារាងទី 17៖ បំណែងចែកក្រេឌីតរួម ៤ឆ្នាំ*

| ល.រ | បណ្តុំ/មុខវិជ្ជាសិក្សា | ឆ្នាំទី១ | | ឆ្នាំទី២ | | ឆ្នាំទី៣ | | ឆ្នាំទី៤ | | ក្រេឌីតសរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | |
| 1. ការសិក្សាពីការអប់រំ (៣០ក្រេឌីត) | | ៦ | ៨ | ៧ | ៦ | ០ | ៣ | ០ | ០ | ៣០ |
| | ចិត្តវិទ្យាអប់រំ៖ ទ្រឹស្តី និងការអនុវត្តសម្រាប់ការរៀននិងបង្រៀន (១ និង ២) | - | ៣ | - | - | - | ៣ | - | - | ៦ |
| | ការវាយតម្លៃការសិក្សា | - | - | - | ៣ | - | - | - | - | ៣ |
| | ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ | - | - | ២ | - | - | - | - | - | ២ |
| | មូលដ្ឋានគ្រឹះនៃការអប់រំ | ៣ | - | - | - | - | - | - | - | ៣ |
| | គរុកោសល្យ និងការបង្រៀន | - | - | ៣ | - | - | - | - | - | ៣ |
| | អប់រំសុខភាព និងអប់រំកាយនិងកីឡា | - | ៣ | - | - | - | - | - | - | ៣ |
| | មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សា និងការអនុវត្ត | - | - | ២ | - | - | - | - | - | ២ |
| | ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន | ៣ | - | - | ៣ | - | - | - | - | ៦ |
| | បំណិនជីវិត ការប្រែប្រួលអាកាសធាតុ បណ្ណាល័យ និងអក្ខរសោស្ត្រអំណាន | - | ២ | - | - | - | - | - | - | ២ |
| 2. ចំណេះដឹងលើមុខវិជ្ជា (២២ ក្រេឌីត) | | ៩ | ៦ | ០ | ៤ | ៣ | ០ | ០ | ០ | ២២ |
| ភាសាខ្មែរ | មូលដ្ឋានគ្រឹះអក្សរសាស្ត្រខ្មែរ (វេយ្យាករណ៍ និង សំណេរតែងសេចក្តី) | ៣ | - | - | - | - | - | - | - | ៣ |
| | មូលដ្ឋានគ្រឹះអក្សរសាស្ត្រខ្មែរ (អក្សរសិល្ប៍ និងតែងសេចក្តី) | - | ៣ | - | - | - | - | - | - | ៣ |
| គណិតវិទ្យា | មូលដ្ឋានគ្រឹះគណិតវិទ្យានៅបឋមសិក្សា | ៣ | - | - | - | - | - | - | - | ៣ |
| | ការពង្រឹងចំណេះដឹងគណិតវិទ្យា | - | - | - | - | ៣ | - | - | - | ៣ |
| វិទ្យាសាស្ត្រ | មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សា (រូបវិទ្យា គីមីវិទ្យា ជីវវិទ្យា) | - | ៣ | - | - | - | - | - | - | ៣ |
| | មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សា (ផែនដីវិទ្យា ការអប់រំបរិស្ថាន) | - | - | - | ២ | - | - | - | - | ២ |
| សិក្សាសង្គម | មូលដ្ឋានគ្រឹះសិក្សាសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា) | ៣ | - | - | - | - | - | - | - | ៣ |

| ល.រ | បណ្តុំ/មុខវិជ្ជាសិក្សា | ឆ្នាំទី១ | | ឆ្នាំទី២ | | ឆ្នាំទី៣ | | ឆ្នាំទី៤ | | ក្រេឌីតសរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | |
| | មូលដ្ឋានគ្រឹះមុខវិជ្ជាសិក្សាសង្គម (សីលធម៌ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) | - | - | - | ២ | - | - | - | - | ២ |
| **3. ការសិក្សាពីកម្មវិធីសិក្សា (៤៥ក្រេឌីត)** | | ៣ | ០ | ១២ | ៤ | ១២ | ៦ | ៥ | ៣ | ៤៥ |
| ភាសាខ្មែរ | វិធីបង្រៀនភាសាខ្មែរ អាន-សរសេរថ្នាក់ទី១ | - | - | ៣ | - | - | - | - | - | ៣ |
| | វិធីបង្រៀនភាសាខ្មែរ អាន-សរសេរថ្នាក់ទី២ និង៣ | - | - | - | ២ | - | - | - | - | ២ |
| | វិធីបង្រៀនភាសាខ្មែរថ្នាក់ទី៤ ដល់ ៦ | - | - | - | - | - | ៣ | - | - | ៣ |
| | ការវាយតម្លៃការសិក្សាភាសាខ្មែរនៅបឋមសិក្សា | - | - | - | - | - | - | - | ៣ | ៣ |
| គណិតវិទ្យា | ការបង្រៀន និងរៀនគណិតវិទ្យា I | ៣ | - | - | - | - | - | - | - | ៣ |
| | ការបង្រៀន និងរៀនគណិតវិទ្យា II | - | - | ៣ | - | - | - | - | - | ៣ |
| | ការបង្រៀន និងរៀនគណិតវិទ្យា III | - | - | - | - | ៣ | - | - | - | ៣ |
| | ការវាយតម្លៃការសិក្សាគណិតវិទ្យានៅបឋមសិក្សា | - | - | - | - | - | - | ២ | - | ២ |
| វិទ្យាសាស្ត្រ | ការសិក្សាកម្មវិធីសិក្សា និងការអនុវត្តវិទ្យាសាស្ត្រសម្រាប់បឋមសិក្សា | - | - | ៣ | - | - | - | - | - | ៣ |
| | គរុកោសល្យសម្រាប់បឋមសិក្សា និងការវាយតម្លៃលើមុខវិជ្ជាវិទ្យាសាស្ត្រនៅបឋមសិក្សា | - | - | - | - | ៣ | - | - | - | ៣ |
| | នវានុវត្តន៍ក្នុងការរៀបចំ និងអនុវត្តគម្រោងសម្រាប់វិទ្យាសាស្ត្រនៅបឋមសិក្សា | - | - | - | - | - | - | ៣ | - | ៣ |
| សិក្សាសង្គម | ការបង្រៀន និងរៀនសិក្សាសង្គមនៅបឋមសិក្សា | - | - | ៣ | - | - | - | - | - | ៣ |
| | វិធីសាស្ត្របង្រៀន និងការវាយតម្លៃមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា | - | - | - | - | ៣ | - | - | - | ៣ |
| | បញ្ញត្តិ និងការអប់រំសិល្បៈ (គំនូរ-ហត្ថកម្ម) | - | - | - | ២ | - | - | - | - | ២ |
| | បញ្ញត្តិ និងការអប់រំសិល្បៈ (តន្ត្រី-របាំ) | - | - | - | - | - | ៣ | - | - | ៣ |
| ភាសបរទេស | វិធីសាស្ត្របង្រៀនភាសាបរទេសនៅបឋមសិក្សា | - | - | - | - | ៣ | - | - | - | ៣ |
| **4. កម្មសិក្សាគរុកោសល្យ (២២ក្រេឌីត)** | | ០ | ២ | ០ | ៥ | ០ | ៥ | ០ | ១០ | ២២ |
| | ការដកស្រង់បទពិសោធនៅសាលារៀន | - | ២ | - | - | - | - | - | - | ២ |

| ល.រ | បណ្តុំ/មុខវិជ្ជាសិក្សា | ឆ្នាំទី១ | | ឆ្នាំទី២ | | ឆ្នាំទី៣ | | ឆ្នាំទី៤ | | ក្រេឌីតសរុប |
|---|---|---|---|---|---|---|---|---|---|---|
| | | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | ឆ ១ | ឆ ២ | |
| | ភាពជាអ្នកជំនួយការបង្រៀន | - | - | - | ៥ | - | - | - | - | ៥ |
| | ការអនុវត្តការបង្រៀន ១ | - | - | - | - | - | ៥ | - | - | ៥ |
| | ការអនុវត្តការបង្រៀន ២ | - | - | - | - | - | - | - | ១០ | ១០ |
| 5. ការស្រាវជ្រាវ (៦ ក្រេឌីត) | | ០ | ០ | ០ | ០ | ៣ | ០ | ០ | ៣ | ៦ |
| | ការស្រាវជ្រាវអប់រំ | - | - | - | - | ៣ | - | - | - | ៣ |
| | គម្រោងស្រាវជ្រាវប្រតិបត្តិ | - | - | - | - | - | - | - | ៣ | ៣ |
| សរុប | | ១៨ | ១៦ | ១៩ | ១៩ | ១៨ | ១៤ | ៥ | ១៦ | ១២៥ |

# ជំពូកទី៣

## ការវាយតម្លៃ

ការវាយតម្លៃការសិក្សាទូទៅ និងការប្រឡងត្រូវអនុវត្តតាមលក្ខខណ្ឌរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀនដែលបានកំណត់ដោយផ្អែកលើសេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៣.១. មធ្យមភាគពិន្ទុនិទ្ទេស (GPA)

រូបមន្តគណនារកមធ្យមនៃពិន្ទុនិទ្ទេសសរុប(GPA) គឺមធ្យមភាគនៃពិន្ទុនិទ្ទេសសរុប(GPA) ស្មើនឹងផលបូកសរុបរវាងផលគុណនៃពិន្ទុនិទ្ទេស (Grade Point-P) និងតម្លៃក្រេឌីតនៃមុខវិជ្ជានីមួយៗ (Attempted Credit Value-C) ចែកនឹងផលបូកសរុបនៃតម្លៃក្រេឌីតដែលត្រូវយកពីគ្រប់មុខវិជ្ជា។

$$GPA = \frac{\sum(P \times C)}{\sum C}$$

បន្ទាប់ពីបញ្ចប់ការសិក្សាតាមមុខវិជ្ជានីមួយៗ គរុនិស្សិតត្រូវចូលរួមវាយតម្លៃភាពពេញចិត្ត (Satisfaction Survey) នូវមុខវិជ្ជា និងគ្រូឧទ្ទេសទទួលបន្ទុក ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំតាមមុខវិជ្ជានីមួយៗ។

ការវាយតម្លៃផ្ទៃក្នុង ធ្វើឡើងដោយការិយាល័យធានាគុណភាពផ្ទៃក្នុងនៃគ្រឹះស្ថានអប់រំគ្រូបង្រៀនក្នុងគោលបំណងធានាឱ្យបាននូវគុណភាព ប្រសិទ្ធភាព និងភាពឆ្លើយតបនឹងបច្ចុប្បន្នភាពនៃកម្មវិធីអប់រំ។

### ៣.២. ប្រព័ន្ធពិន្ទុ និងនិទ្ទេស

គរុនិស្សិតម្នាក់ៗត្រូវតែបញ្ចប់មុខវិជ្ជានីមួយៗ ដែលតម្រូវនៅក្នុងកម្មវិធីអប់រំ។ រាល់ការវាយតម្លៃគរុនិស្សិតត្រូវបានកំណត់តាមរយៈការឱ្យពិន្ទុ និងការដាក់មូលវិចារដូចមានចែងខាងក្រោម៖

**ក- ការដាក់ពិន្ទុ៖** ពិន្ទុត្រូវបានកំណត់ពី ០០.០០ ដល់ ១០០.០០ [មធ្យមភាគ នៃពិន្ទុនិទ្ទេសសរុប (Grade Point Average ឬ GPA) ដែលកំណត់ថាជាប់ គឺចាប់ពីមធ្យមពិន្ទុ៥០.០០ ឬ GPA ២.០០ ឡើងទៅ]។

**ខ- ការដាក់មូលវិចារ៖** ការដាក់មូលវិចារត្រូវឱ្យស្របទៅនឹងពិន្ទុដូចខាងក្រោម៖

*តារាងទី 18៖ ប្រព័ន្ធពិន្ទុ និងនិទ្ទេស*

| ពិន្ទុជាភាគរយ% | និទ្ទេសជាអក្សរ | ពិន្ទុនិទ្ទេស | និទ្ទេស |
|---|---|---|---|
| ៨៥%-១០០% | A | ៤.០០ | ល្អប្រសើរ |
| ៨០%-៨៤% | B+ | ៣.៥០ | ល្អណាស់ |
| ៧០%-៧៩% | B | ៣.០០ | ល្អ |
| ៦៥%-៦៩% | C+ | ២.៥០ | ល្អបង្គួរ |
| ៥០%-៦៤% | C | ២.០០ | មធ្យម |
| <៥០% | D | ១.៥០ | ធ្លាក់ |

ការវាយតម្លៃការសិក្សា ត្រូវអនុវត្តតាមលក្ខខណ្ឌរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀនដែលរួមមានការវាយតម្លៃជាដំណាក់ (Formative Assessment) និងការវាយតម្លៃបញ្ចប់ (Summative Assessment)។

## ៣.៣. ការវាយតម្លៃមុខវិជ្ជាបង្រៀន

ការវាយតម្លៃលើមុខវិជ្ជាបង្រៀនរួមមាន ទម្រង់ផ្សេងៗជាច្រើនដូចជា វត្តមាន ការចូលរួមសកម្មភាពសិក្សា កិច្ចការសំណេរ ការធ្វើបទបង្ហាញ តេស្ត និងការប្រឡងបញ្ចប់មុខវិជ្ជា។

*តារាងទី 19៖ ការវាយតម្លៃមុខវិជ្ជាបង្រៀន*

| ល.រ. | ទម្រង់នៃការវាយតម្លៃ | ភាគរយ (%) |
|---|---|---|
| ១ | វត្តមាន | ១០ |
| ២ | ការចូលរួមសកម្មភាពសិក្សា | ២០ |
| ៣ | ការវាយតម្លៃអំឡុងពេលសិក្សា | ៣០ |
| ៤ | ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា | ៤០ |
| | សរុប | ១០០ |

** សម្គាល់៖ គ្រូឧទ្ទេសមានសិទ្ធិក្នុងការរៀបចំការវាយតម្លៃតាមមុខវិជ្ជាទទួលបន្ទុកដោយមានភាពបត់បែន និងឆ្លើយតបជាមួយលទ្ធផលសិក្សារំពឹងទុកនៃមុខវិជ្ជានីមួយៗ។*

### ៣.៣.១. វត្តមាន

វត្តមានរបស់គរុនិស្សិត ត្រូវបានវាយតម្លៃតាមរយៈការចូលរួមស្តាប់ បទឧទ្ទេស ការបង្ហាត់បង្ហាញ និងព្រឹត្តិការណ៍ដទៃទៀតតាមការកំណត់នៃមុខវិជ្ជាសិក្សា។

គរុនិស្សិតដែលបានចូលរៀនមុខវិជ្ជាសិក្សានីមួយៗ ចាំបាច់ត្រូវមានវត្តមានយ៉ាងតិចបំផុត ៨០% ដើម្បីអាចចូលរួមប្រឡងបញ្ចប់មុខវិជ្ជាសិក្សា ប៉ុន្តែមានករណីលើកលែងចំពោះគរុនិស្សិតមួយចំនួនដោយផ្អែកលើហេតុផលផ្នែកវេជ្ជសាស្ត្រផ្ទាល់ខ្លួន ឬកាលៈទេសៈសមស្របដទៃទៀត អាស្រ័យទៅតាមបទប្បញ្ញត្តិរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៣.៣.២. ការចូលរួមសកម្មភាពសិក្សា

ការវាយតម្លៃសកម្មភាពសិក្សា ផ្អែកលើភាពទៀងទាត់ និងភាពសកម្មនៃការចូលរួម ប្រកបដោយគុណភាពរបស់គរុនិស្សិតក្នុងអំឡុងពេលសិក្សាដូចជា ការផ្លាស់ប្តូរបទពិសោធជាមួយគ្រូឧទ្ទេស និងមិត្តរួមក្រុមក្នុងការចែករំលែកគំនិត ធនធានសិក្សា ការផ្តល់មតិយោបល់ និងព័ត៌មានត្រឡប់។

### ៣.៣.៣. ការវាយតម្លៃអំឡុងពេលសិក្សា

ការវាយតម្លៃអំឡុងពេលសិក្សាផ្អែកលើគុណភាពនៃកិច្ចការដែលបានទទួលតាមរយៈ ការវាយតម្លៃតាមដំណាក់មានដូចជា៖

- កិច្ចការសំណេរ
- ការធ្វើបទបង្ហាញ
- គម្រោង/កិច្ចការស្រាវជ្រាវ
- ការធ្វើតេស្តពាក់កណ្តាលឆមាស

ការរៀបចំកិច្ចការវាយតម្លៃគួរតែបន្សីគ្នាជាមួយកិច្ចការវាយតម្លៃស្វ័យឆ្លុះបញ្ចាំង ដែលត្រូវបានប្រើប្រាស់ជាផ្នែកមួយនៃការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីឱ្យគរុនិស្សិតត្រៀមខ្លួនសម្រាប់អាជីពវិជ្ជាជីវៈដោយផ្អែកលើការសិក្សាពេញមួយជីវិត។

គរុនិស្សិតដែលបានចូលរៀនមុខវិជ្ជាសិក្សានីមួយៗត្រូវបំពេញ និង/ឬ ប្រគល់កិច្ចការប្រឡងទាំងអស់ដើម្បីអាចចូលរួមប្រឡងបញ្ចប់មុខវិជ្ជាសិក្សា។

### ៣.៣.៤. ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សា

ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សាជាការវាយតម្លៃបញ្ចប់នៃមុខវិជ្ជាសិក្សាទាំងអស់។ ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សានឹងត្រូវធ្វើឡើងនៅសប្តាហ៍ប្រឡងនៃឆមាស ឬឆ្នាំសិក្សានីមួយៗដែលមុខវិជ្ជាសិក្សាត្រូវបានបង្រៀន។

ការប្រឡងបញ្ចប់មុខវិជ្ជាសិក្សាមានដូចជា៖

- កិច្ចការសំណេរ
- កិច្ចការសំណួរចម្លើយខ្លីៗ
- កិច្ចការសំណួរចម្លើយពហុជ្រើសរើស
- កិច្ចការស្រាវជ្រាវ
- ការធ្វើបទបង្ហាញ

គរុនិស្សិតដែលបានចូលរៀនមុខវិជ្ជាសិក្សានីមួយៗ ចាំបាច់ត្រូវប្រឡងបញ្ចប់មុខវិជ្ជានោះដើម្បីបានទទួលពិន្ទុបញ្ចប់។ គរុនិស្សិតប្រឡងធ្លាក់មុខវិជ្ជាសិក្សាណាមួយ ពួកគេអាចប្រឡងឡើងវិញបានតែមួយលើកប៉ុណ្ណោះ។ ក្នុងករណីប្រឡងឡើងវិញធ្លាក់ គរុនិស្សិតត្រូវរៀនមុខវិជ្ជានោះឡើងវិញ ដើម្បីមានសិទ្ធិប្រឡងបញ្ចប់។ គរុនិស្សិតលួចចម្លងស្នាដៃនៃកិច្ចការណាមួយនឹងត្រូវទទួលពិន្ទុសូន្យលើកិច្ចការនោះ។

## ៣.៤. ការវាយតម្លៃកម្មសិក្សាគរុកោសល្យ

ការវាយតម្លៃកម្មសិក្សាគរុកោសល្យរួមមាន វត្តមាន សកម្មភាពចូលរួមធ្វើកិច្ចតែងការបង្រៀន ការបង្រៀនក្នុងថ្នាក់រៀន និងសកម្មភាពសាលារៀនដទៃទៀត ព្រមទាំងការរក្សាទុកផលបត្រកម្មសិក្សាគរុកោសល្យផ្អែកលើផែនការសិក្សាវិជ្ជាជីវៈ។

សមាសភាគកម្មសិក្សាគរុកោសល្យនីមួយៗ នឹងត្រូវបានវាយតម្លៃដោយគ្រឹះស្ថានអប់រំគ្រូបង្រៀនសហការជាមួយសាលារៀនដែលគរុនិស្សិតចុះកម្មសិក្សាគរុកោសល្យ។

*តារាងទី 20៖ ការវាយតម្លៃកម្មសិក្សាគរុកោសល្យ*

| ល.រ. | ទម្រង់នៃការវាយតម្លៃ | ភាគរយ (%) |
|---|---|---|
| ១ | វត្តមានអំឡុងពេលកម្មសិក្សាគរុកោសល្យ | ១០ |
| ២ | សកម្មភាពចូលរួមក្នុងកម្មសិក្សាគរុកោសល្យ | ២០ |
| ៣ | ការវាយតម្លៃអំឡុងពេលបំពេញកម្មសិក្សាគរុកោសល្យ | ៣០ |
| ៤ | ផលបត្រកម្មសិក្សាគរុកោសល្យ | ៤០ |
| | សរុប | ១០០ |

### ៣.៤.១. វត្តមានអំឡុងពេលកម្មសិក្សាគរុកោសល្យ

វត្តមានក្នុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវវាយតម្លៃផ្អែកលើ វត្តមានរបស់គរុនិស្សិតចូលរួមការប្រឹក្សាគរុកោសល្យ ការសង្កេតថ្នាក់រៀន រយៈពេលនៃការបង្រៀនតាមកាលវិភាគដែលបានកំណត់ ការប្រជុំចាំបាច់ និងព្រឹត្តិការណ៍នានានៅសាលារៀន។

គរុនិស្សិតត្រូវមានវត្តមានយ៉ាងតិច ៨០% សម្រាប់កម្មសិក្សាគរុកោសល្យប្រចាំឆ្នាំនីមួយៗ ដើម្បីអាចចូលរួមប្រឡងបញ្ចប់កម្មវិធីអប់រំ។ ប៉ុន្តែមានករណីលើកលែងចំពោះបុគ្គលមួយចំនួនដោយសារហេតុផលផ្អែកវេជ្ជសាស្ត្រ ហេតុផលផ្ទាល់ខ្លួន ឬដោយសារកាលៈទេសៈសមស្របដទៃទៀត អាស្រ័យទៅតាមបទប្បញ្ញត្តិរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

### ៣.៤.២ សកម្មភាពចូលរួមអំឡុងពេលកម្មសិក្សាគរុកោសល្យ

សកម្មភាពចូលរួមអំឡុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវវាយតម្លៃផ្អែកលើការចូលរួម និងគុណភាពនៃការចូលរួមរបស់គរុនិស្សិតនៅក្នុងអំឡុងពេលចុះកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗ។

សកម្មភាពចូលរួមក្នុងកម្មសិក្សាគរុកោសល្យរួមមាន កម្រិតនៃការចូលរួមអនុវត្តសកម្មភាពតាមសាលារៀនដែលបានកំណត់ ការផ្លាស់ប្ដូរបទពិសោធជាមួយគ្រូបង្រៀននៅសាលារៀន និងមិត្តរួមក្រុម ការចូលរួមចំណែកក្នុងវគ្គវាយតម្លៃលទ្ធផលកម្មសិក្សាគរុកោសល្យ ការចែករំលែកគំនិតឬធនធាន ការផ្ដល់មតិយោបល់ និងព័ត៌មានត្រឡប់ទៅកាន់គ្រូបង្រៀននៅសាលារៀននិងមិត្តរួមក្រុម។

ការវាយតម្លៃសកម្មភាពចូលរួមកម្មសិក្សាគរុកោសល្យផ្ដោតលើកម្រិតចូលរួមរបស់គរុនិស្សិត៖

- អំឡុងពេល និងក្រោយពេលសង្កេតការបង្រៀន
- នៅក្នុងការប្រឹក្សាគរុកោសល្យ ឬសកម្មភាពពិភាក្សាក្រុម
- នៅក្នុងសកម្មភាពសហការរវាងមិត្តរួមក្រុម
- គរុនិស្សិតនៅក្នុងសាលារៀន ឬសហគមន៍

### ៣.៤.៣. ការវាយតម្លៃអំឡុងពេលកម្មសិក្សាគរុកោសល្យ

ការវាយតម្លៃអំឡុងពេលកម្មសិក្សាគរុកោសល្យនឹងត្រូវផ្អែកលើ គុណភាពកិច្ចការ ឬពិន្ទុដែលទទួលបានពីការបំពេញកិច្ចការក្នុងអំឡុងពេលចុះកម្មសិក្សាគរុកោសល្យ ដែលជាផ្នែកមួយនៃការវាយតម្លៃកិច្ចការតាមដំណាក់ក្នុងឆ្នាំនីមួយៗ។

ការវាយតម្លៃអំឡុងពេលបំពេញកម្មសិក្សាគរុកោសល្យរួមមាន៖

- ការវាយតម្លៃលើកិច្ចតែងការបង្រៀន ផែនការសកម្មភាព ឬធនធានឯកសារដទៃទៀត
- ការវាយតម្លៃលើការអនុវត្តការបង្រៀន ដែលមានការសង្កេត និងវាយតម្លៃ
- ការវាយតម្លៃផ្អែកលើកម្រិតនៃការអភិវឌ្ឍវិជ្ជាជីវៈនៅអំឡុងពេលកម្មសិក្សាគរុកោសល្យ
- ការវាយតម្លៃផ្អែកលើការវាយតម្លៃវិជ្ជាជីវៈជាប្រចាំ ដោយនាយកសាលារៀន

### ៣.៤.៤. ផលបត្រកម្មសិក្សាគរុកោសល្យ

ការវាយតម្លៃបញ្ចប់នៃសមាសភាគកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗផ្អែកលើ ការប្រគល់ផលបត្រកម្មសិក្សាគរុកោសល្យ។

គរុនិស្សិតត្រូវរក្សាផលបត្ររបស់ខ្លួនក្នុងអំឡុងពេលកម្មសិក្សាគរុកោសល្យក្នុងឆ្នាំនីមួយៗ។ ផលបត្រកម្មសិក្សាគរុកោសល្យ រួមមានភស្តុតាងនៃសកម្មភាពដែលបានអនុវត្ត កិច្ចតែងការបង្រៀន និងការបង្រៀនរួមទាំងការឆ្លុះបញ្ចាំងពីចំណុចខ្លាំង ចំណុចខ្វះខាត និងការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន។

មាតិកាផលបត្រកម្មសិក្សាគរុកោសល្យអាចរួមមាន៖

- កំណត់ហេតុការបង្រៀនប្រចាំថ្ងៃដែលឆ្លុះបញ្ចាំងពីសកម្មភាពដែលបានអនុវត្ត និងមេរៀនទទួលបាន
- កំណត់ត្រាពីមេរៀនដែលបានសង្កេត
- កិច្ចតែងការបង្រៀន ផែនការសកម្មភាព និងធនធានដទៃទៀត
- ខ្លឹមសារសង្ខេបនៃការប្រឹក្សាគរុកោសល្យ សកម្មភាពជាមួយមិត្តរួមក្រុម
- ឯកសារថតចម្លងការវាយតម្លៃពីគ្រូណែនាំ និងការសង្កេតការបង្រៀនដែលបានវាយតម្លៃ
- កំណត់ត្រាស្វ័យឆ្លុះបញ្ចាំងផ្តោតលើចំណុចខ្លាំង ចំណុចខ្វះខាត និងចំណុចដែលត្រូវកែលម្អ និងវិធីក្នុងការធ្វើការកែលម្អ
- ការសង្កេតលើទិដ្ឋភាពដទៃទៀតនៃជីវិតពិតក្នុងសាលារៀនរួមមាន ការគ្រប់គ្រងនិងរដ្ឋបាល និងការចូលរួមរបស់សហគមន៍ ទំនាក់ទំនងរវាងឪពុកម្តាយជាមួយគ្រូបង្រៀន។ល។

ទម្រង់ផលបត្រកម្មសិក្សាគរុកោសល្យ ត្រូវផ្អែកលើផែនការសិក្សាវិជ្ជាជីវៈសម្រាប់គ្រូបង្រៀនម្នាក់ៗដែលតម្រូវដោយសៀវភៅណែនាំស្តីពីការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំរបស់ក្រសួងអប់រំ យុវជន និងកីឡា។

## ៣.៤. ការវាយតម្លៃលើគម្រោងស្រាវជ្រាវប្រតិបត្តិ

គរុនិស្សិតទាំងអស់ត្រូវរៀបចំ និងអនុវត្តគម្រោងស្រាវជ្រាវប្រតិបត្តិដែលមានការទទួលស្គាល់ទាក់ទងនឹងការអនុវត្តការបង្រៀន សមស្របនឹងបរិបទសាលារៀនដែលពួកគេចុះកម្មសិក្សាគរុកោសល្យ។

គម្រោងស្រាវជ្រាវរបស់គរុនិស្សិតត្រូវត្រួតពិនិត្យដោយគ្រូឧទ្ទេសនៅគ្រឹះស្ថានអប់រំគ្រូបង្រៀន ដែលជាគ្រូឧទ្ទេសដឹកនាំការស្រាវជ្រាវ។ គ្រូឧទ្ទេសដឹកនាំការស្រាវជ្រាវត្រូវផ្តល់ព័ត៌មានត្រឡប់ មតិយោបល់ជាលាយលក្ខណ៍អក្សរ និងការណែនាំទៀងទាត់ដល់គរុនិស្សិត ដើម្បីធានាថាពួកគេធ្វើការស្រាវជ្រាវបានត្រឹមត្រូវ និងសរសេររបាយការណ៍ស្រាវជ្រាវប្រកបដោយគុណភាព។ គរុនិស្សិតនឹងត្រូវទទួលបានការប្រឹក្សាគរុកោសល្យពីគ្រូឧទ្ទេសដែលនឹងគាំទ្រការអនុវត្តការស្រាវជ្រាវរបស់ពួកគេ។

***តារាងទី 21៖ ការវាយតម្លៃគម្រោងស្រាវជ្រាវប្រតិបត្តិ***

| ល.រ. | ទម្រង់នៃការវាយតម្លៃ | ភាគរយ (%) |
|---|---|---|
| ១ | សំណើស្រាវជ្រាវ | ១០ |
| ២ | ការវាយតម្លៃពីវឌ្ឍនភាពនៃការស្រាវជ្រាវ (ជួបប្រជុំជាមួយគ្រូដឹកនាំយ៉ាងតិចចំនួន ៤ដង) | ២០ |
| ៣ | ការប្រគល់របាយការណ៍ និងការការពារការស្រាវជ្រាវបញ្ចប់ | ៧០ |
| | សរុប | ១០០ |

បន្ទាប់ពីបានពិភាក្សាលើកដំបូងជាមួយគ្រូឧទ្ទេសដឹកនាំ គរុនិស្សិតត្រូវដាក់សេចក្តីព្រាងដំបូងនៃសំណើស្រាវជ្រាវរបស់ខ្លួនដើម្បីទទួលបានការត្រួតពិនិត្យ។ សំណើស្រាវជ្រាវរួមមាន៖

- ប្រធានបទស្រាវជ្រាវ

- គម្រោងស្រាវជ្រាវ
- ក្របខ័ណ្ឌពេលវេលានៃការស្រាវជ្រាវ

ក្រោយពីទទួលបានមតិយោបល់កែលម្អ គរុនិស្សិតត្រូវប្រគល់សេចក្តីព្រាងចុងក្រោយនៃសំណើស្រាវជ្រាវ។ គរុនិស្សិតត្រូវប្រគល់របាយការណ៍ស្រាវជ្រាវចុងក្រោយ ក្រោយពីទទួលបានមតិយោបល់កែលម្អក្នុងកិច្ចប្រជុំវាយតម្លៃចុងក្រោយ។

គរុនិស្សិតត្រូវបញ្ចប់ និងប្រគល់របាយការណ៍ស្រាវជ្រាវមុននឹងអាចចូលប្រឡងបញ្ចប់ការសិក្សាបាន។ ករណីមិនបានបំពេញគ្រប់លក្ខខណ្ឌក្នុងការស្រាវជ្រាវទេ គរុនិស្សិតមិនអាចបញ្ចប់ការសិក្សាបានទេ។

## ៣.៥. ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយា

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់គរុនិស្សិតម្នាក់ៗ ត្រូវបានប្រមូលផ្តុំលើការគោរពវិន័យ ការមករៀនទៀងទាត់ ការយកចិត្តទុកដាក់ក្នុងការសិក្សា ការខិតខំស្រាវជ្រាវ ការអនុវត្តភារកិច្ច និងស្មារតីសាមគ្គីភាពនៅក្នុងថ្នាក់ ក្នុងនិងក្រៅគ្រឹះស្ថានអប់រំគ្រូបង្រៀន។

ការវាយតម្លៃលើវិន័យ សីលធម៌ ឥរិយាបថ និងអាកប្បកិរិយារបស់គរុនិស្សិតម្នាក់ៗ ជាយោបល់ឯកភាពមតិភាគច្រើនដាច់ខាតរបស់ក្រុមប្រឹក្សាវិន័យ ដោយផ្អែកលើលក្ខណៈសម្បត្តិជាក់ស្តែងរបស់គរុនិស្សិតម្នាក់ៗ និងបទបញ្ជាផ្ទៃក្នុងរបស់គ្រឹះស្ថានអប់រំគ្រូបង្រៀន។

## ៣.៦. ការផ្តល់សញ្ញាបត្រ

គរុនិស្សិតត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ដើម្បីបញ្ចប់ការសិក្សា និងទទួលបានសញ្ញាបត្រ៖

1. សិក្សាគ្រប់ចំនួនក្រេឌីតដែលបានកំណត់ក្នុងកម្មវិធីអប់រំគ្រូបង្រៀនបឋមសិក្សាកម្រិតបរិញ្ញាបត្រតាមប្រព័ន្ធ ១២+៤ ដោយជោគជ័យ
2. បំពេញកម្មសិក្សាគរុកោសល្យដោយជោគជ័យ
3. មានចំណេះដឹងភាសាបរទេសកម្រិតមធ្យម (Intermediate level)។ គ្រឹះស្ថានអប់រំគ្រូបង្រៀនត្រូវវាយតម្លៃកម្រិតសមត្ថភាពភាសាបរទេសរបស់គរុនិស្សិតនៅដើមឆ្នាំទី១ និងរៀបចំវគ្គសិក្សាតាមតម្រូវការរបស់គរុនិស្សិតឱ្យមានសមត្ថភាពភាសាបរទេសកម្រិតមធ្យមនៅត្រឹមដើមឆ្នាំទី៣ ដើម្បីទទួលការអប់រំវិធីសាស្ត្របង្រៀនចំនួន ៣ក្រេឌីតនៅឆមាសទី១ ឆ្នាំទី៣
4. ការពារបញ្ចប់គម្រោងស្រាវជ្រាវប្រតិបត្តិដោយជោគជ័យ
5. ប្រឡងបញ្ចប់កម្មវិធីអប់រំគ្រូបង្រៀនជាប់ជាស្ថាពរ

គរុនិស្សិតដែលបានបញ្ចប់ការសិក្សាដោយជោគជ័យ នឹងទទួលបាន **បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនបឋមសិក្សា** ។

# ជំពូកទី៤

# ការពណ៌នាមុខវិជ្ជា

## ៤.១. ការសិក្សាពីការអប់រំ (៣០ ក្រេឌីត)

### ៤.១.១. ចិត្តវិទ្យាអប់រំ [៦ (៦-០-១២)]

មុខវិជ្ជាចិត្តវិទ្យាអប់រំផ្ដល់នូវទិដ្ឋភាពទូទៅនៃចិត្តវិទ្យា ចិត្តវិទ្យាអប់រំ និងការអនុវត្តទ្រឹស្ដីចិត្តវិទ្យានិងទ្រឹស្ដីសិក្សាក្នុងការបង្រៀន និងរៀននៅកម្រិតបឋមសិក្សា។ គរុនិស្សិតនឹងស្គាល់ខ្លួនឯង និងសិស្សរបស់ពួកគេបានច្បាស់តាមរយៈការសិក្សាអំពីទ្រឹស្ដីសំខាន់ៗនៃចិត្តវិទ្យាអប់រំ។ មុខវិជ្ជានេះមានគោលបំណងផ្ដល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានក្នុងការកសាងគុណតម្លៃ ការអភិវឌ្ឍសមត្ថភាពសង្គមនិងអារម្មណ៍ និងបំណិនសតវត្សរ៍ទី២១របស់អ្នកសិក្សា ដើម្បីសម្រេចបាននូវលទ្ធផលនៃការអប់រំដែលចង់បាន ពោលគឺជាអ្នកសិក្សាបែបស្វ័យដឹកនាំជាមនុស្សមានទំនុកចិត្ត ជាពលរដ្ឋដែលយកចិត្តទុកដាក់ និងជាអ្នករួមចំណែកយ៉ាងសកម្មក្នុងការលើកកម្ពស់គុណភាពអប់រំ។ មុខវិជ្ជានេះចែកជា២ផ្នែកសំខាន់ៗគឺ ផ្នែកទី១ (ចិត្តវិទ្យាអប់រំ១) និងផ្នែកទី២ (ចិត្តវិទ្យាអប់រំ២)។

#### *៤.១.១.១ ចិត្តវិទ្យាអប់រំ១ [៣ (៣-០-៦)]*

មុខវិជ្ជាចិត្តវិទ្យាអប់រំមួយ មានគោលបំណងផ្ដល់ជូនគរុនិស្សិតនូវទិដ្ឋភាពទូទៅនៃចិត្តវិទ្យាអប់រំសម្រាប់ការបង្រៀននិងរៀន ឫសគល់និងភាពចាំបាច់នៃចិត្តវិទ្យាអប់រំ សម្រាប់តួនាទីជាគ្រូបង្រៀន។ លើសពីនេះ មុខវិជ្ជានេះ ជួយដល់គរុនិស្សិតឱ្យយល់ដឹងស៊ីជម្រៅលើខ្លឹមសារមេរៀនដូចជា ការអភិវឌ្ឍពុទ្ធិនិងភាសា ការអភិវឌ្ឍសីលធម៌បុគ្គលនិងផ្លូវចិត្ត ភាពចម្រុះនៃការសិក្សារបស់សិស្ស ការអប់រំសម្រាប់បរិយាបន្ន ទ្រឹស្ដីនានានៃចិត្តវិទ្យាអប់រំ។ ក្រោយពីសិក្សាមុខវិជ្ជានេះចប់ គរុនិស្សិតនឹងមានចំណេះដឹងមូលដ្ឋានគ្រឹះនៃចិត្តវិទ្យាអប់រំ និងមានសមត្ថភាពយកបញ្ញត្តិនិងទ្រឹស្ដីនានាទៅអនុវត្តក្នុងការបង្រៀន និងរៀន។

#### *៤.១.១.២. ចិត្តវិទ្យាអប់រំ២ [៣ (៣-០-៦)]*

មុខវិជ្ជាចិត្តវិទ្យាអប់រំ២ មានបំណងផ្ដល់ជូនគរុនិស្សិតនូវការសិក្សាបន្ថែមលើទ្រឹស្ដីនានា បន្តពីទ្រឹស្ដីមុនៗក្នុងចិត្តវិទ្យាអប់រំ១ ដូចជា ទ្រឹស្ដីស្ថាបនានិយម ទ្រឹស្ដីមនុស្សនិយម ជាដើម។ លើសពីនេះទៅទៀត មុខវិជ្ជានេះក៏គ្របដណ្ដប់លើខ្លឹមសារមេរៀននិងបញ្ញត្តិនៃការដោះស្រាយបញ្ហានិងការបង្កើតថ្មី ការបង្រៀននិងរៀន ចិត្តសង្គម (Socio-emotional learning) ដំណើរការក្រុមក្នុងការបង្រៀន ទស្សនទានពុទ្ធិ-សង្គមនៃការសិក្សា និងការលើកទឹកចិត្តសិស្ស ការរៀបចំនិងគ្រប់គ្រងការបង្រៀន និងរៀន សហគមន៍សិក្សាប្រកបដោយប្រសិទ្ធភាព ឥទ្ធិពលនៃការរំពឹងទុករបស់គ្រូបង្រៀន និងការសម្របខ្លួននៅក្នុងសាលារៀនជាដើម។ ក្រោយពីការសិក្សាមុខវិជ្ជានេះចប់ គរុនិស្សិតមានសមត្ថភាពប្រើប្រាស់បញ្ញត្តិ និងការអនុវត្តនានាក្នុងមុខវិជ្ជានេះ ដើម្បីបង្កើនលទ្ធផលសិក្សា និងសុខុមាលភាពផ្លូវចិត្តរបស់សិស្ស។

### ៤.១.២. ការវាយតម្លៃការសិក្សា [៣ (៣-០-៦)]

មុខវិជ្ជាការវាយតម្លៃការសិក្សា ត្រូវបានរៀបចំឡើងដើម្បីបំពេញតម្រូវការផ្នែកវិធីសាស្ត្រក្នុងការវាយតម្លៃព្រមទាំងផ្ដល់ដល់គរុនិស្សិតនូវសមត្ថភាពក្នុងការវាយតម្លៃសិស្សដែលមានសមត្ថភាពចម្រុះ និងវប្បធម៌ផ្សេងគ្នា។ មុខវិជ្ជានេះរួមបញ្ចូលនូវទិដ្ឋភាពទូទៅនៃការវាយតម្លៃ វិធីរៀបចំនិងផលិតឧបករណ៍វាយតម្លៃដែលមានសុពលភាព និងភាពជឿជាក់។ ក្របខ័ណ្ឌសំណួរតេស្តវង្វាយតម្លៃលទ្ធផលសិក្សារបស់សិស្សបឋមសិក្សា នៅតំបន់អាស៊ីអាគ្នេយ៍

(SEA-PLM) និងការបង្កើតតេស្ត SEA-PLM ផ្នែកអំណាន សំណេរ និងគណិតវិទ្យា ត្រូវបានបញ្ចូលក្នុងកម្មវិធីសិក្សា ដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃ SEA-PLM និងដើម្បីលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សឱ្យស្របជាមួយ តេស្តស្តង់ដាជាតិកម្រិតបឋមសិក្សា។ មុខវិជ្ជានេះក៏ផ្តល់ដល់គរុនិស្សិតនូវចំណេះដឹងក្នុងការបង្កើតលក្ខណវិនិច្ឆ័យនៃ ការវាយតម្លៃលើបំណិនចិត្តចលករ (Psychomotor Skills) ឬបំណិនអនុវត្ត (Performance Skills) និងបំណិន (skills) (ការគិត ការបង្ហាញហេតុផល ការអនុវត្ត ការសម្តែង បទបង្ហាញ និងកិច្ចការ គម្រោង) និងឥរិយាបថរបស់ សិស្សផងដែរ។ បន្ទាប់ពីសិក្សាមុខវិជ្ជានេះចប់ គរុនិស្សិតនឹងមានចំណេះដឹង និងបំណិនក្នុងការបង្កើតតេស្តស្តង់ដា សរសេរនិទ្ទេសបទសម្រាប់វាយតម្លៃបំណិននិងឥរិយាបថ និងរៀបចំតេស្តលក្ខណៈតំបន់លើផ្នែកអំណាន សំណេរ និងគណិតវិទ្យាប្រកបដោយសុពលភាព ភាពជឿជាក់ និងមានប្រសិទ្ធភាព។

### ៤.១.៣. ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ [២ (២-០-៤)]

មុខវិជ្ជា ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈ មានបំណងផ្តល់ជូនគរុនិស្សិតនូវការអនុវត្តការងារជាគ្រូបង្រៀន និងការឆ្លុះបញ្ចាំងក្រោយការបង្រៀននិងរៀន។ មុខវិជ្ជានេះគ្របដណ្តប់ ការប្រតិបត្តិវិជ្ជាជីវៈរបស់គរុនិស្សិតដែល នឹងក្លាយជាគ្រូបង្រៀននៅថ្ងៃអនាគត ដោយមានការណែនាំពីគ្រូឧទ្ទេសដឹកនាំ និងគ្រូណែនាំ។ តាមរយៈការសិក្សា មុខវិជ្ជានេះ គរុនិស្សិតនឹងទទួលនូវការអភិវឌ្ឍបំណិន ការឆ្លុះបញ្ចាំងពីជំនឿរបស់ពួកគេ ការស្វែងយល់កាន់តែ ច្បាស់ពីដំណើរការ ការសាកសួរក្នុងម៉ោងបង្រៀនរបស់ពួកគេ ដើម្បីបង្កើនទំនាក់ទំនងល្អនិងភាពជិតស្និត ជាមួយមាតាបិតាសិស្ស និងការបំពេញផលបត្ររបស់ពួកគេផងដែរ។ ក្រោយពីសិក្សាមុខវិជ្ជានេះចប់ គរុនិស្សិត មានសមត្ថភាពផ្សារភ្ជាប់ទ្រឹស្តី ការប្រតិបត្តិ និងឆ្លុះបញ្ចាំងវិជ្ជាជីវៈជាគ្រូបង្រៀននៅថ្ងៃអនាគតរបស់ពួកគេប្រកប ដោយភាពជឿជាក់។

### ៤.១.៤. មូលដ្ឋានគ្រឹះនៃការអប់រំ [៣ (៣-០-៦)]

មុខវិជ្ជានេះ ផ្តោតលើការអប់រំទូទៅ បរិបទសង្គម និងចំណេះដឹងមូលដ្ឋាននៃការអប់រំក្នុងកម្មវិធីអប់រំ គ្រូបង្រៀន។ មុខវិជ្ជានេះ ក៏បង្ហាញពី សិទ្ធិកុមារ ច្បាប់ និងអនុសញ្ញាអន្តរជាតិ ដើម្បីជំរុញឱ្យគរុនិស្សិតមានទំនួល ខុសត្រូវ និងគិតអំពីផលប៉ះពាល់នៃការសម្រេចចិត្ត។ ទន្ទឹមនឹងនេះផងដែរ មុខវិជ្ជានេះផ្តល់ជូនគរុនិស្សិតនូវការ សិក្សាប្រកបដោយនិរន្តរភាព ការផ្តល់អំណាចឱ្យមនុស្ស ការបំលែងរបៀបគិត និងរបៀបធ្វើ។ មុខវិជ្ជានេះរួម បញ្ចូលការសិក្សាយេនឌ័រ ការជួញដូរផ្លូវភេទ ការអប់រំបរិយាបន្ន និងការបង្រៀនថ្នាក់គួប ការសិក្សាផ្តោតលើបំណិន សតវត្សរ៍ទី២១ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ការប្រៀបធៀបការអប់រំអន្តរជាតិ និងការគ្រប់គ្រង សាលារៀន។ ខ្លឹមសារក្នុងមុខវិជ្ជានេះក៏រួមបញ្ចូល រដ្ឋបាលសាលារៀន សីលធម៌វិជ្ជាជីវៈ ការគ្រប់គ្រងថ្នាក់រៀន និងបំណិនដោះស្រាយបញ្ហាប្រឈមក្នុងការបង្រៀន ដើម្បីគាំទ្រកុមារដែលមានតម្រូវការពិសេស ប្រកបដោយ បរិយាបន្ន។ ក្រោយពីសិក្សាមុខវិជ្ជានេះចប់ គរុនិស្សិតទទួលបានចំណេះដឹង ការយល់ដឹង និងបំណិនមូលដ្ឋាន គ្រឹះនៃការអប់រំដែលជាប្រយោជន៍សម្រាប់ពួកគេក្នុងការសិក្សាមុខវិជ្ជានានាក្នុងកម្មវិធីអប់រំគ្រូបង្រៀន។

### ៤.១.៥. គរុកោសល្យ និងការបង្រៀន [៣ (៣-០-៦)]

មុខវិជ្ជាគរុកោសល្យ និងការបង្រៀន មានបំណងផ្តល់ជូនគរុនិស្សិតនូវការយល់ដឹងស៊ីជម្រៅអំពីការបង្រៀន តាមបែបសិស្សមជ្ឈមណ្ឌល ដោយយកចិត្តទុកដាក់ចំពោះភាពរីករាយ និងភាពចម្រុះនៃសិស្សនៅក្នុងបរិបទបច្ចុប្បន្ន និងផ្តល់ជូននូវបំណិនអន្តរបុគ្គល ការគិតស៊ីជម្រៅ ការវិភាគ និងការទទួលខុសត្រូវក្នុងអាជីពជាគ្រូបង្រៀន។ ខ្លឹមសារមេរៀនក្នុងមុខវិជ្ជានេះរួមបញ្ចូលទាំងបញ្ញត្តិ គោលការណ៍ ទ្រឹស្តី និងការអនុវត្តវិធីសាស្ត្របង្រៀនសមស្រប

សម្រាប់ថ្នាក់បឋមសិក្សា។ គរុនិស្សិតនឹងបានសិក្សាអំពីទិដ្ឋភាពទូទៅនៃការគ្រប់គ្រងថ្នាក់រៀន ការអភិវឌ្ឍយុទ្ធសាស្ត្រដើម្បីបង្កើតបរិយាកាសសិក្សាល្អ និងលើកកម្ពស់ការចូលរួមសកម្មរបស់សិស្ស។ បន្ទាប់ពីបញ្ចប់ការសិក្សាមុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពក្នុងការរៀបចំនិងអនុវត្តកម្មវិធីបង្រៀនដែលសមស្របនឹងតម្រូវការនិងលក្ខណៈពិសេសរបស់សិស្ស បង្កើតបរិយាកាសសិក្សាដែលមានការចូលរួមនិងគាំទ្រ និងមានសមត្ថភាពអភិវឌ្ឍជំនាញទំនាក់ទំនង វិជ្ជាជីវៈ ការគ្រប់គ្រងថ្នាក់រៀនប្រកបដោយប្រសិទ្ធភាព និងការទទួលខុសត្រូវខ្ពស់ក្នុងការបង្រៀននៅកម្រិតបឋមសិក្សា។

### ៤.១.៦. អប់រំសុខភាព និងអប់រំកាយនិងកីឡា [៣ (២-២-៥)]

មុខវិជ្ជានេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹង និងបំណិនជាមូលដ្ឋាននៃសុខភាពសាលារៀន និងការអប់រំកាយនិងកីឡា សម្រាប់លើកកម្ពស់សុខុមាលភាពសិក្សានៅកម្រិតបឋមសិក្សា។ នៅក្នុងមុខវិជ្ជានេះ គរុនិស្សិតត្រូវសិក្សាមុខវិជ្ជារងចំនួនពីររួមមាន អប់រំសុខភាព និងអប់រំកាយនិងកីឡា។ ផ្នែកអប់រំសុខភាពផ្តោតលើគោលបំណងនៃសុខភាពសាលារៀន ការលូតលាស់និងមុខងាររាងកាយ អនាម័យនិងការការពារពីជំងឺ ផលប៉ះពាល់និងការពិនិត្យតាមដានសុខភាព សុខភាពផ្លូវភេទ សុខភាពផ្លូវចិត្ត ការសង្គ្រោះបឋម ការគ្រប់គ្រងសុវត្ថិភាពសាលារៀន និងសេវានិងប្រព័ន្ធសុខភាពសាលារៀន។ ផ្នែកអប់រំកាយនិងកីឡាផ្តោតលើគោលការណ៍និងការរៀបចំថ្នាក់អប់រំកាយនិងកីឡា អប់រំកាយតាមចង្វាក់ភ្លេង កាយសម្ព័ន្ធ អត្តពលកម្ម ល្បែងបាល់ និងតេស្តកាយសម្បទា។ ការសិក្សាត្រូវផ្សារភ្ជាប់ទៅនឹងការផលិតសម្ភារឧបទេសដោយប្រើធនធានដែលមាននៅក្នុងមូលដ្ឋាន និងការអនុវត្តជាក់ស្តែងក្នុងថ្នាក់ ឬក្រៅថ្នាក់។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពមូលដ្ឋានក្នុងការគ្រប់គ្រងសុខភាព ក៏ដូចជាសុវត្ថិភាពផ្ទាល់ខ្លួន និងមានទំនុកចិត្តក្នុងការអប់រំសុខភាពសិក្សា និងអប់រំកាយនិងកីឡាដល់សិស្សានុសិស្សនៅកម្រិតបឋមសិក្សា។

### ៤.១.៧. មូលដ្ឋានគ្រឹះនៃកម្មវិធីសិក្សានិងការអនុវត្ត [២ (២-០-៤)]

មុខវិជ្ជានេះរៀបចំឡើងដើម្បីផ្តល់ជូនគរុនិស្សិតនូវនិយមន័យ គោលការណ៍ បញ្ញត្តិគន្លឹះៗ ទ្រឹស្តី និងសមាសភាគកម្មវិធីសិក្សា ប្រភេទកម្មវិធីសិក្សា ដំណើរការអភិវឌ្ឍកម្មវិធីសិក្សា ការអនុវត្តកម្មវិធីសិក្សា ការវិភាគ និងវាយតម្លៃកម្មវិធីសិក្សា បញ្ហាប្រឈម និងនិន្នាការនៃការអភិវឌ្ឍកម្មវិធីសិក្សា ព្រមទាំងជំហានគំរូនៃដំណើរការអភិវឌ្ឍកម្មវិធីសិក្សា ការអភិវឌ្ឍកម្មវិធីសិក្សាដោយយកសាលារៀនជាមូលដ្ឋាន និងការកែលម្អឱ្យកម្មវិធីសិក្សាកាន់តែមានភាពប្រសើរ។ ក្រោយពីសិក្សាមុខវិជ្ជានេះចប់ គរុនិស្សិតមានសមត្ថភាព វាយតម្លៃកម្មវិធីសិក្សាលម្អិត សង្គតិភាពនៃសមាសភាគនានាក្នុងកម្មវិធីសិក្សាលម្អិត និងសៀវភៅសិក្សាគោល អនុវត្តកម្មវិធីសិក្សាល្អប្រសើរ សម្របសម្រួលការអនុវត្តការបង្រៀននិងរៀន និងសាកល្បងបង្កើតមុខវិជ្ជាបន្ថែមសមស្របនឹងបរិបទបង្រៀនជាក់ស្តែងរបស់ពួកគេ។

### ៤.១.៨. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀននិងរៀន [៦ (៤-៤-១០)]

#### *៤.១.៨.១. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀន និងរៀន I [៣ (២-២-៥)]*

មុខវិជ្ជានេះមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងឧបករណ៍ AI ប្រកបដោយប្រសិទ្ធភាព និងជំរុញការសហការនិងការទំនាក់ទំនង

ដើម្បីលើកកម្ពស់ការសិក្សាប្រកបដោយអត្ថន័យជាមួយនឹងការប្រើប្រាស់បច្ចេកវិទ្យា និង AI នៅក្នុងបរិយាកាសសិក្សាក្នុងដំណើរការបង្រៀន និងរៀន។ មុខវិជ្ជានេះផ្តោតលើ (១) ការរៀបចំផែនការបង្រៀន និងឯកសារបង្រៀននិង រៀនដោយប្រើប្រាស់ AI (២) ការធ្វើការបែបសហការដោយប្រើអ៊ីនធឺណិត និង (៣) ការប្រើប្រាស់ឯកសារ នានាដោយមិនរំលោភលើសិទ្ធិអ្នកនិពន្ធដែលជាតម្រូវការពិសេសសម្រាប់គ្រូបង្រៀនក្នុងសតវត្សរ៍ទី២១ និងភាពជាពលរដ្ឋឌីជីថល។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងយល់ច្បាស់ពីការប្រើបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក៏ដូចជាសក្តានុពល និងការប្រើប្រាស់ AI ប្រកបដោយក្រមសីលធម៌ និងការទទួលខុសត្រូវក្នុងបរិបទ អប់រំ និងការអនុវត្តល្អបំផុត ដើម្បីបង្កើនការចូលរួមរបស់សិស្ស លើកកម្ពស់ការរៀនសកម្ម តាមរយៈការធ្វើបទបង្ហាញ និងការអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀន។

### *៤.១.៨.២. ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់ការបង្រៀននិងរៀន II [៣ (២-២-៥)]*

មុខវិជ្ជានេះមានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹង និងជំនាញក្នុងការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការបង្រៀននិងរៀន។ មុខវិជ្ជានេះផ្តោតលើការបង្កើតឯកសារបង្រៀននិងរៀន ការគិតតាមបែបកុំព្យូទ័រ ការស្រាវជ្រាវ និងការប្រើប្រាស់ឯកសារនានាដែលជាតម្រូវការពិសេសសម្រាប់គ្រូបង្រៀនក្នុងសតវត្សរ៍ទី២១ និងភាពជាពលរដ្ឋឌីជីថល។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងយល់ច្បាស់ពីការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ និងការអនុវត្តល្អបំផុតដើម្បីបង្កើនការចូលរួមរបស់សិស្ស លើកកម្ពស់ការរៀនសកម្មតាមរយៈការធ្វើបទបង្ហាញ និងការអនុវត្តជាក់ស្តែងក្នុងថ្នាក់រៀន។

### ៤.១.៩. បំណិនជីវិត ការប្រែប្រួលអាកាសធាតុ បណ្ណាល័យ និងអក្ខរសាស្ត្រអំណាន [២ (១-២-៣)]

មុខវិជ្ជានេះត្រូវបានបែងចែកជាម៉ូឌុលចម្បងៗចំនួន៤ ដែលរួមមាន បំណិនជីវិត ការប្រែប្រួលអាកាសធាតុ បណ្ណាល័យ និងអក្ខរសាស្ត្រអំណាន។ មុខវិជ្ជានេះ រៀបចំឡើងដើម្បីអភិវឌ្ឍសមត្ថភាព គរុនិស្សិតឱ្យមានការយល់ដឹងស៊ីជម្រៅលើការអប់រំបំណិនជីវិត ការប្រែប្រួលអាកាសធាតុ អក្ខរសាស្ត្រអំណាន និងបណ្ណាល័យនៅបឋមសិក្សា។ តាមរយៈការសិក្សាមុខវិជ្ជានេះ គរុនិស្សិតនឹងសិក្សាអំពី បញ្ញត្តិ ទ្រឹស្តីពីការអប់រំបំណិនជីវិត និងវិធីសាស្ត្របង្រៀនតាមបែបសកម្ម ដែលលើកកម្ពស់បំណិនសតវត្សរ៍ទី២១ ដល់សិស្សបឋមសិក្សា ដូចបានកំណត់ក្នុងក្របខ័ណ្ឌកម្មវិធីសិក្សាដូចជា ការច្នៃប្រឌិត ការរិះគិតពិចារណា ការដោះស្រាយបញ្ហា ការគ្រប់គ្រងខ្លួនឯង ភាពធន់ ការទំនាក់ទំនង ការសហការ ការចរចា ការគោរពពហុភាព សមានចិត្ត ជាដើម។ លើសពីនេះ គរុនិស្សិតនឹងទទួលបានចំណេះដឹងអំពីការប្រែប្រួលអាកាសធាតុ ការបង្កើតបណ្ណាល័យ ការដឹកនាំសកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ និងការប្រើប្រាស់វិធីសាស្ត្រអានបែបសកម្ម។ សកម្មភាពបង្រៀន និងរៀនសំខាន់ៗក្នុងមុខវិជ្ជានេះរួមមាន ការធ្វើបឋកថា ការធ្វើផែនទីគំនិត ការពិភាក្សាក្រុម ការសម្តែងតួ ការធ្វើបទបង្ហាញ ការសរសេរ កិច្ចតែងការ ការហ្វឹកហាត់បង្រៀនសាកល្បង និងការឆ្លុះបញ្ចាំងពីបទពិសោធរៀន។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពបង្រៀនសិស្សបឋមសិក្សាលើមុខវិជ្ជាបំណិនជីវិត បង្កើតនិងគ្រប់គ្រងបណ្ណាល័យជ្រុងថ្នាក់ឬបន្ទប់ដឹកនាំសកម្មភាពអំណានក្នុងម៉ោងបណ្ណាល័យ និងបញ្ជ្រាបវិធីសាស្ត្រអំណានបែបសកម្មនិងការប្រែប្រួលអាកាសធាតុក្នុងមុខវិជ្ជាដទៃ។

### ៤.២. ចំណេះដឹងលើមុខវិជ្ជា (២២ ក្រេឌីត)

ចំណេះដឹងលើមុខវិជ្ជា គ្របដណ្ដប់លើមុខវិជ្ជាសិក្សាទាំងឡាយណាដែលផ្ដល់ឱ្យគរុនិស្សិតនូវការណែនាំអំពីខ្លឹមសារ បញ្ញត្តិ និងគោលការណ៍នៃមុខវិជ្ជាដូចដែលមាននៅក្នុងកម្មវិធីសិក្សាបឋមសិក្សា។ មុខវិជ្ជាសិក្សានៃបណ្ដុំមុខវិជ្ជាសិក្សាចំណេះដឹងលើមុខវិជ្ជា ពង្រឹងចំណេះដឹងគរុនិស្សិតលើខ្លឹមសារមុខវិជ្ជាទាំងអស់សម្រាប់ការបង្រៀននៅកម្រិតសាលារៀន។

គោលបំណងនៃបណ្ដុំមុខវិជ្ជាសិក្សាចំណេះដឹងលើមុខវិជ្ជា ដើម្បីផ្ដល់ឱ្យគរុនិស្សិតនូវចំណេះដឹងលើមុខវិជ្ជាដែលត្រូវការសម្រាប់បង្រៀននៅបឋមសិក្សា ដោយផ្អែកលើប្រធានបទ ដែលមាននៅក្នុងកម្មវិធីសិក្សាថ្នាក់ជាតិ។

#### ៤.២.១. ភាសាខ្មែរ [ ៦ (៤-៤-១០)]

មុខវិជ្ជានេះ មានគោលបំណងផ្ដល់ឱ្យគរុនិស្សិតនូវចំណេះដឹងមូលដ្ឋានភាសាខ្មែរ សម្រាប់ការបង្រៀននៅមឋមសិក្សា និងការដោះស្រាយបញ្ហាដែលជួបប្រចាំថ្ងៃប្រកបដោយភាពបត់បែន។ ជាមួយនឹងការផ្ដល់មូលដ្ឋានដ៏រឹងមាំលើចំណេះដឹងភាសាខ្មែរ គរុនិស្សិតក៏នឹងទទួលបានបំណិនចាំបាច់មួយចំនួនដែលឆ្លើយតបនឹងបំណិនគ្រូបង្រៀនសតវត្សរ៍ទី២១ ផងដែរ ដើម្បីជាទុនក្នុងការបញ្ជ្រាបខ្លឹមសារមេរៀននិងចំណេះដឹងផ្សេងទៀតទៅនឹងការបង្រៀនសិស្សជាក់ស្ដែងនៅបឋមសិក្សាឱ្យមានប្រសិទ្ធភាព និងប្រសិទ្ធផល។ គរុនិស្សិតនឹងត្រូវអភិវឌ្ឍបំណិនទាំងបួនក្នុងបរិបទដែលខ្លួនជួបប្រទះក្នុងជីវភាពរស់នៅ ដោយផ្អែកលើឯកសារព័ត៌មាននិងសកម្មភាពដែលប៉ះពាល់នឹងជីវភាពរស់នៅរបស់ខ្លួន។ គរុនិស្សិតនឹងត្រូវចូលរួមពិភាក្សានិងធ្វើបទបង្ហាញលើប្រធានបទដែលពាក់ព័ន្ធនឹងជីវភាពរស់នៅ និងស្រាវជ្រាវលើឯកសារនានា ដើម្បីពង្រឹងចំណេះដឹងភាសាផ្នែកវេយ្យាករណ៍ អក្សរសិល្ប៍ និងតែងសេចក្ដី។

##### *៤.២.១.១. មូលដ្ឋានគ្រឹះវេយ្យាករណ៍ និងសំណេរតែងសេចក្ដី [៣ (២-២-៥)]*

មុខវិជ្ជា "មូលដ្ឋានគ្រឹះវេយ្យាករណ៍ និងសំណេរតែងសេចក្ដី" នេះត្រូវបានរៀបចំឡើងសម្រាប់គរុនិស្សិតថ្នាក់បរិញ្ញាបត្រអប់រំវិជ្ជាជីវៈគ្រូបង្រៀនក្នុងការអភិវឌ្ឍមូលដ្ឋានគ្រឹះដ៏រឹងមាំលើចំណេះដឹង និងបំណិនវេយ្យាករណ៍ និងសំណេរតែងសេចក្ដី។ តាមរយៈការស្វែងយល់ពីក្បួនច្បាប់វេយ្យាករណ៍ខ្មែរ គរុនិស្សិតនឹងទទួលបានការយល់ដឹងអំពីសូរនិងសទ្ទតាវិទ្យា វចនវិទ្យា សម្ព័ន្ធវិទ្យា និងន័យវិទ្យា។ បន្ថែមលើវេយ្យាករណ៍ មុខវិជ្ជានេះក៏សង្កត់ធ្ងន់លើការអភិវឌ្ឍសំណេរតែងសេចក្ដី ពិសេសតែងសេចក្ដីពណ៌នា ដោយលើកទឹកចិត្តគរុនិស្សិតបញ្ចេញគំនិតរបស់ពួកគេយ៉ាងច្បាស់ និងស៊ីសង្វាក់គ្នានៃគំនិតតាមប្រធានបទនីមួយៗ។ គរុនិស្សិតនឹងចូលរួមក្នុងការធ្វើលំហាត់សរសេរផ្សេងៗ រួមទាំងការសរសេរកថាខណ្ឌ អត្ថបទ និងសំណេរបែបច្នៃប្រឌិត ក្នុងគោលបំណងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងការប្រាស្រ័យទាក់ទងប្រកបដោយប្រសិទ្ធភាពក្នុងទម្រង់ជាលាយលក្ខណ៍អក្សរ។ ជាមួយគ្នានេះ ចំណេះដឹងលើវេយ្យាករណ៍ជាមួយនឹងកិច្ចការសរសេរជាក់ស្ដែង គរុនិស្សិតនឹងមិនត្រឹមតែស្គាល់ស្រៈ ព្យញ្ជនៈ ល្បះខុសត្រូវ និងការអនុវត្តគោលគំនិតវេយ្យាករណ៍ប៉ុណ្ណោះទេ ប៉ុន្តែពួកគេថែមទាំងពេញចិត្តចំពោះសារៈសំខាន់ លើសមាសភាគនៃការសិក្សាលើចំណុចនីមួយៗប្រកបដោយប្រសិទ្ធភាពក្នុងជីវិតសិក្សា និងវិជ្ជាជីវៈរបស់ពួកគេ។ នៅចុងបញ្ចប់នៃមុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពលើកកម្ពស់ទាំងជំនាញភាសាប្រកបដោយភាពច្នៃប្រឌិត សម្រាប់បង្រៀនបន្តនាពេលអនាគតក្នុងវិស័យអប់រំ អក្សរសាស្ត្រ និងផ្លូវមុខវិជ្ជា។

### *៤.២.១.២. មូលដ្ឋានគ្រឹះអក្សរសិល្ប៍ និងការតែងនិពន្ធ [៣ (២-២-៥)]*

មុខវិជ្ជា "មូលដ្ឋានគ្រឹះអក្សរសិល្ប៍និងការតែងនិពន្ធ" មានគោលបំណងផ្តល់ឱ្យគរុនិស្សិតនូវទ្រឹស្តីអក្សរសិល្ប៍ និងការតែងនិពន្ធដែលត្រូវបានរៀបចំជាពិសេសឆ្លើយតបនឹងតម្រូវការរបស់សិស្សបឋមសិក្សា។ មុខវិជ្ជានេះផ្តោតលើទ្រឹស្តីអក្សរសិល្ប៍ ប្រវត្តិអក្សរសិល្ប៍ និងវិភាគអក្សរសិល្ប៍។ ជាមួយគ្នានេះដែរ មុខវិជ្ជានេះក៏សិក្សាពីធាតុសំខាន់ៗនៃអក្សរសិល្ប៍កុមារ រួមទាំងរចនាសម្ពន្ធនៃការនិទានរឿង ដោយប្រើភាសាសមស្របសម្រាប់កុមារ។ មុខវិជ្ជានេះនឹងផ្តោតលើការយល់ដឹងពីរបៀបដែលអក្សរសិល្ប៍អាចបង្កើត ការអភិវឌ្ឍ ការយល់ដឹង និងអារម្មណ៍ចំពោះកុមារក៏ដូចជាវិធីសាស្ត្រសម្រាប់ជំរុញភាពច្នៃប្រឌិត និងការស្រមើស្រមៃតាមរយៈការនិទានរឿង។ គរុនិស្សិតក៏នឹងចូលរួមអនុវត្តលំហាត់ជាក់ស្តែងផងដែរដើម្បីបង្កើតរឿងថ្មីដែលផ្តោតលើ កុមារកម្រិតបឋមសិក្សាដោយបញ្ចូលទាំងគោលការណ៍ច្នៃប្រឌិត និងគរុកោសល្យ។ នៅចុងបញ្ចប់នៃមុខវិជ្ជានេះ គរុនិស្សិតមានមូលដ្ឋានគ្រឹះអក្សរសិល្ប៍ និងការតែងនិពន្ធស្នាដៃអក្សរសិល្ប៍ដើម្បីបង្រៀនប្រកបដោយប្រសិទ្ធភាពនៅកម្រិតបឋមសិក្សា ក្នុងគោលបំណងអភិវឌ្ឍអំណាននិងបំណិនផ្សេងៗដែលជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់កុមារ។

### **៤.២.២. គណិតវិទ្យា [៦ (៦-០-១២)]**

### *៤.២.២.១. មូលដ្ឋានគ្រឹះគណិតវិទ្យានៅបឋមសិក្សា [៣ (៣-០-៦)]*

មុខវិជ្ជានេះមានគោលបំណងឱ្យគរុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋានគ្រឹះគណិតវិទ្យា សម្រាប់ការបង្រៀននៅកម្រិតបឋមសិក្សា។ នៅក្នុងមុខវិជ្ជានេះ គរុនិស្សិតត្រូវសិក្សាមុខវិជ្ជារងទាំងប្រាំដែលរួមមាននព្វន្តពីជគណិត រង្វាស់រង្វាល់ ធរណីមាត្រ និងស្ថិតិ។ មូលដ្ឋានគ្រឹះនៃមុខវិជ្ជារងនីមួយៗដូចជា សញ្ញាណ និយមន័យ លក្ខណៈ និងទំនាក់ទំនងរវាងខ្លឹមសារមួយទៅខ្លឹមសារមួយទៀតត្រូវបានលើកយកមកសិក្សាដើម្បីឱ្យគរុនិស្សិតស្វែងយល់ខ្លឹមសារទាំងនោះបានច្បាស់លាស់។ លើសពីនេះ គរុនិស្សិតក៏សិក្សាផងដែរអំពីយុទ្ធសាស្ត្រក្នុងការដោះស្រាយចំណោទ ដែលមានបញ្ចូលបរិបទដើម្បីបន្សីគ្នាជាមួយនឹងការប្រកួតប្រជែងថ្នាក់អន្តរជាតិ ក៏ដូចជាការផ្សារភ្ជាប់ខ្លឹមសារមេរៀនឱ្យត្រូវទៅនឹងបំណិនសតវត្សទី២១។ ក្រោយបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងទទួលបានចំណេះដឹងស៊ីជម្រៅលើមូលដ្ឋានគ្រឹះនៃមុខវិជ្ជារងទាំងប្រាំ និងអនុវត្តក្នុងការបង្រៀនសិស្សប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាព។

### *៤.២.២.២ ការពង្រឹងចំណេះដឹងគណិតវិទ្យា [៣ (៣-០-៦)]*

មុខវិជ្ជានេះមានគោលបំណងឱ្យគរុនិស្សិតទទួលបានចំណេះដឹងស៊ីជម្រៅលើមូលដ្ឋានគ្រឹះគណិតវិទ្យាសម្រាប់ផ្សារភ្ជាប់នៅកម្រិតអនុវិទ្យាល័យ និងពង្រីកចំណេះដឹងបន្ថែមដើម្បីឱ្យគ្រូបង្រៀននៅកម្រិតបឋមសិក្សាមានចំណេះដឹងកាន់តែទូលំទូលាយ។ ខ្លឹមសារដែលត្រូវសិក្សាក្នុងមុខវិជ្ជានេះរួមមាន ចំនួនគត់ ចំនួនគត់រ៉ឺឡាទីបប្រភាគ ចំនួនទសភាគ ផលធៀប ភាគរយ សមាមាត្រ រង្វាស់រង្វាល់ ធរណីមាត្រ និងប្រូបាបនិងស្ថិតិ។ លើសពីនេះ គរុនិស្សិតក៏សិក្សាផងដែរអំពីការគិតបែបគណិតវិទ្យា និងការគិតសមហេតុផល ដែលជាចំណុចសំខាន់នាំឱ្យមានការច្នៃប្រឌិត និងនវានុវត្តន៍។ ក្រោយបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតទទួលបានចំណេះដឹងស៊ីជម្រៅលើមុខវិជ្ជារងទាំងប្រាំ ដែលចាំបាច់សម្រាប់ផ្សារភ្ជាប់នៅកម្រិតខ្ពស់ និងអនុវត្តក្នុងការបង្រៀនសិស្សប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាព។

### ៤.២.៣. វិទ្យាសាស្ត្រ [៥ (៤-២-៩)]

#### *៤.២.៣.១. មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សា (រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា) [៣ (៣-០-៦)]*

មុខវិជ្ជានេះផ្ដល់នូវមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងពីចំណេះដឹងមូលដ្ឋានវិទ្យាសាស្ត្រ ដើម្បីប្រើប្រាស់ឱ្យមានទំនាក់ទំនងជាមួយនឹងកម្មវិធីសិក្សាបឋមសិក្សា។ មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សាផ្ដោតលើផ្នែកសំខាន់ៗនៃការពន្យល់បកស្រាយ និងអនុវត្តជាក់ស្ដែងលើបញ្ញត្តិវិទ្យាសាស្ត្រដូចជា រូបវិទ្យា គីមីវិទ្យា និងជីវវិទ្យា ដែលមានទំនាក់ទំនងនឹងការរៀបចំមេរៀនវិទ្យាសាស្ត្រនៅកម្រិតបឋមសិក្សា។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងទទួលបាននូវចំណេះដឹងមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រក្នុងការបង្រៀននៅកម្រិតបឋមសិក្សាច្បាស់លាស់ និងការគិតបែបវិទ្យាសាស្ត្រជាច្រើនទៀតដែលជំរុញនិងការលើកទឹកចិត្តដល់គរុនិស្សិតក្នុងការរៀនសូត្រផងដែរ។

#### *៤.២.៣.២. មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សា (ផែនដី និងបរិស្ថានវិទ្យា) [២ (២-០-៤)]*

មុខវិជ្ជានេះផ្ដល់នូវមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងពីចំណេះដឹងមូលដ្ឋានវិទ្យាសាស្ត្រ ដើម្បីប្រើប្រាស់ឱ្យមានទំនាក់ទំនងជាមួយនឹងកម្មវិធីសិក្សាបឋមសិក្សា។ មូលដ្ឋានគ្រឹះវិទ្យាសាស្ត្រនៅបឋមសិក្សាផ្ដោតលើផ្នែកសំខាន់ៗនៃការពន្យល់បកស្រាយ និងអនុវត្តជាក់ស្ដែងលើបញ្ញត្តិវិទ្យាសាស្ត្រលើមុខវិជ្ជាផែនដី និងបរិស្ថានវិទ្យា ដែលមានទំនាក់ទំនងនឹងការរៀបចំមេរៀនវិទ្យាសាស្ត្រនៅកម្រិតបឋមសិក្សា។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងទទួលបាននូវចំណេះដឹងមូលដ្ឋានគ្រឹះវិទ្យាសាស្ត្រក្នុងការបង្រៀននៅកម្រិតបឋមសិក្សាច្បាស់លាស់ និងការគិតបែបវិទ្យាសាស្ត្រជាច្រើនទៀត ដែលជំរុញនិងការលើកទឹកចិត្តដល់គរុនិស្សិតក្នុងការរៀនសូត្រផងដែរ។

### ៤.២.៤. សិក្សាសង្គម [៥ (៤-២-៩)]

#### *៤.២.៤.១. មូលដ្ឋានគ្រឹះសិក្សាសង្គម (ប្រវត្តិវិទ្យា ភូមិវិទ្យា) [៣ (៣-០-៦)]*

មុខវិជ្ជានេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹងមូលដ្ឋានគ្រឹះសិក្សាសង្គមសម្រាប់ការបង្រៀនសិក្សាសង្គមនៅបឋមសិក្សា។ នៅក្នុងមុខវិជ្ជានេះ គរុនិស្សិតត្រូវសិក្សាមុខវិជ្ជាវងចំនួនពីរគឺ ប្រវត្តិវិទ្យា និងភូមិវិទ្យា។ ផ្នែកប្រវត្តិវិទ្យាផ្ដោតលើប្រវត្តិសាស្ត្រប្រទេសកម្ពុជាចាប់ពីសម័យបុរេប្រវត្តិសាស្ត្រមកដល់សម័យបច្ចុប្បន្ន ដែលនឹងផ្ដល់ដល់គរុនិស្សិតនូវចំណេះដឹងពីការវិវត្តផ្នត់គំនិតរបស់មនុស្សលើផ្នែកនយោបាយ សេដ្ឋកិច្ច សង្គម ដោយផ្សារភ្ជាប់ការអប់រំអន្តរវប្បធម៌ ភាពជាពលរដ្ឋសកម្ម វប្បធម៌សន្តិភាព និងការរួមរស់ដោយសុខដុមជាមួយប្រជាជាតិ តំបន់ និងពិភពលោក។ ផ្នែកភូមិវិទ្យាផ្ដោតលើភូមិវិទ្យារូបទូទៅ ភូមិវិទ្យាសេដ្ឋកិច្ចប្រជាសាស្ត្រ ដែលនឹងផ្ដល់ដល់គរុនិស្សិតនូវចំណេះដឹងទាក់ទងនឹងលក្ខណៈរបស់ផែនដី ការប្រែប្រួលអាកាសធាតុ ទម្រង់ប្រជាសាស្ត្រ សេដ្ឋកិច្ចសង្គម និងការការពារគ្រោះធម្មជាតិ។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំខ្លឹមសារមេរៀនមុខវិជ្ជាប្រវត្តិវិទ្យា និងភូមិវិទ្យា សម្រាប់ការបង្រៀនសិក្សាសង្គមនៅបឋមសិក្សា។

#### *៤.២.៤.២. មូលដ្ឋានគ្រឹះមុខវិជ្ជាសិក្សាសង្គម (សីលធម៌ពលរដ្ឋវិជ្ជា គេហសេដ្ឋកិច្ចវិទ្យា) [២ (១-២-៣)]*

មុខវិជ្ជានេះមានគោលបំណង អភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹងមូលដ្ឋានគ្រឹះសិក្សាសង្គមសម្រាប់ការបង្រៀនសិក្សាសង្គមនៅបឋមសិក្សា។ នៅក្នុងមុខវិជ្ជានេះ គរុនិស្សិតត្រូវសិក្សាមុខវិជ្ជាវងចំនួនពីររួមមាន សីលធម៌ពលរដ្ឋវិជ្ជា និងគេហសេដ្ឋកិច្ចវិទ្យា។ ផ្នែកសីលធម៌ពលរដ្ឋវិជ្ជាផ្ដោតសំខាន់លើការអប់រំតម្លៃ បញ្ញា ឆន្ទៈ សិទ្ធិ និងករណីកិច្ចរបស់ពលរដ្ឋក្នុងការរស់នៅក្នុងសង្គមជាតិ តំបន់ និងពិភពលោក។ ផ្នែកគេហសេដ្ឋកិច្ចវិទ្យាផ្ដោតលើវិជ្ជាដេរប៉ាក់ ធ្វើម្ហូប បដិសណ្ឋារកិច្ច រៀបចំគេហដ្ឋាន និងមូលដ្ឋានគ្រឹះសហគ្រិនភាព ដោយផ្សារភ្ជាប់ការអនុវត្តជាក់ស្ដែងនៅក្នុងថ្នាក់ ឬក្រៅថ្នាក់។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំខ្លឹមសារមេរៀនមុខវិជ្ជាសីលធម៌ពលរដ្ឋវិជ្ជា និងមានបំណិនផ្នែកគេហសេដ្ឋកិច្ចវិទ្យា សម្រាប់ការរស់នៅប្រចាំថ្ងៃ និងការបង្រៀនសិក្សាសង្គមនៅបឋមសិក្សា។

## ៤.៣. ការសិក្សាពីកម្មវិធីសិក្សា (៤៥ ក្រេឌីត)

### ៤.៣.១. ភាសាខ្មែរ [១១ (៧-៨-១៨)]

#### *៤.៣.១.១. វិធីបង្រៀនភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី១ [៣ (២-២-៥)]*

មុខវិជ្ជា វិធីសាស្ត្របង្រៀនភាសាខ្មែរ អាន-សរសេរថ្នាក់ទី១ មានគោលបំណងផ្ដល់ឱ្យគរុនិស្សិតនូវវិធីសាស្ត្របង្រៀនជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍបំណិនអាន និងសរសេរមុខវិជ្ជាភាសាខ្មែរថ្នាក់ទី១។ មុខវិជ្ជានេះសង្កត់ធ្ងន់លើទ្រឹស្ដី និងការអនុវត្តដែលផ្ដល់ជូននូវការយល់ពីយុទ្ធវិធីបង្រៀនប្រកបដោយប្រសិទ្ធភាពដោយផ្ដោតលើសមាសភាគទាំង៥នៃការអាន និងគោលការណ៍នៃការបង្រៀន។ គរុនិស្សិតនឹងទទួលបានបទពិសោធផ្ទាល់ក្នុងការប្រើប្រាស់សម្ភារៈកញ្ចប់អំណាន និងរៀបចំផែនការមេរៀន ការវាយតម្លៃ និងការណែនាំផ្សេងៗស្របតាមស្តង់ដាកម្មវិធីសិក្សាជាតិ ដើម្បីគាំទ្រតម្រូវការសិក្សាបែបបរិយាបន្ន។ នៅចុងបញ្ចប់នៃការសិក្សាមុខវិជ្ជានេះ គរុនិស្សិតនឹងក្លាយជាគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី១ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈគ្រូបង្រៀន។

#### *៤.៣.១.២. វិធីបង្រៀនភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី២និងទី៣ [៣ (២-២-៥)]*

មុខវិជ្ជា ការបង្រៀនភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី២ និងទី៣ មានគោលបំណងផ្ដល់ឱ្យគរុនិស្សិតនូវមូលដ្ឋានគ្រឹះទ្រឹស្ដី និងវិធីសាស្ត្រជាក់ស្ដែងដើម្បីបង្រៀន ការអាន និងការសរសេរជាភាសាខ្មែរប្រកបដោយប្រសិទ្ធភាពដល់សិស្សក្នុងកញ្ចប់អំណានថ្នាក់ទី២ និងទី៣។ មុខវិជ្ជានេះផ្ដោតលើយុទ្ធសាស្ត្រអភិវឌ្ឍបំណិនអក្ខរកម្មដែលសមស្របតាមអាយុ ដោយសង្កត់ធ្ងន់លើសមាសភាគទាំង៥ នៃអំណាន សកម្មភាពគោលទាំង៧ និងគោលការណ៍ទាំង៣ នៃការបង្រៀនសម្រាប់ការអាននិងការសរសេរ (រចនាសម្ពន្ធ ប្រយោគ និងការអានដើម្បីយល់ន័យ)។ គរុនិស្សិតនឹងស្វែងយល់ពីវិធីសាស្ត្របង្រៀនជាច្រើនរួមទាំង ការនិទានរឿងបែបអន្តរកម្ម លំនាំបង្រៀនអំណាន និងលំហាត់សំណេរ ដែលត្រូវបានរៀបចំឡើងដើម្បី ទាក់ទាញសិស្ស និងជំរុញឱ្យមានសេចក្ដីស្រឡាញ់ចំពោះភាសាខ្មែរ។ មុខវិជ្ជានេះនឹងលើកឡើងពីសារៈសំខាន់នៃលំនាំផ្សេងៗគ្នាខ្លះពីថ្នាក់ទី១ ដើម្បីបំពេញតម្រូវការសិក្សាចម្រុះ និងផ្ដល់នូវបច្ចេកទេសសម្រាប់វាយតម្លៃវឌ្ឍនភាពសិស្សក្នុងការអាន និងសរសេរ។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះ គរុនិស្សិតនឹងក្លាយគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរ អាន-សរសេរ ថ្នាក់ទី២និងទី៣ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

#### *៤.៣.១.៣. វិធីបង្រៀនភាសាខ្មែរថ្នាក់ទី៤ ដល់ទី៦ [៣ (២-២-៥)]*

មុខវិជ្ជា "វិធីបង្រៀនភាសាខ្មែរថ្នាក់ទី៤ដល់ទី៦" ផ្ដល់នូវការស្វែងយល់យ៉ាងទូលំទូលាយអំពីវិធីសាស្ត្របង្រៀនសម្រាប់ការអាន និងការសរសេរភាសាខ្មែរដែលរៀបចំជាពិសេសសម្រាប់សិស្សថ្នាក់ទី៤-៦។ មុខវិជ្ជានេះផ្ដោតលើវិធីសាស្ត្របង្រៀនសមត្ថភាពទាំង៤នៃភាសា និងបំណិនផ្សេងៗ ដែលជំរុញការអភិវឌ្ឍការយល់ដឹងភាសា និងសំណេរសម្រាប់ទំនាក់ទំនងនៅកម្រិតបឋមសិក្សា។ មុខវិជ្ជានេះសង្កត់ធ្ងន់លើការផ្លាស់ប្ដូរពីអក្ខរកម្មមូលដ្ឋាន ទៅជាជំនាញអាន យល់ន័យ និងការសរសេរកម្រិតខ្ពស់ ដោយរួមបញ្ចូលលំនាំបង្រៀនផ្សេងៗគ្នា បច្ចេកទេសវាយតម្លៃ និងការរៀបចំកម្មវិធីសិក្សាសម្រាប់បឋមសិក្សាកម្រិតខ្ពស់។ គរុនិស្សិតនឹងរៀនពីរបៀបដើម្បីចូលរួមជាមួយសិស្សនៅក្នុងសកម្មភាពអាន និងសរសេរប្រកបដោយអត្ថន័យដែលជំរុញការគិតប្រកបដោយការត្រិះរិះពិចារណា ភាពច្នៃប្រឌិត និងភាពស្ទាត់ជំនាញភាសា។ តាមរយៈលំហាត់ជាក់ស្ដែង ការធ្វើ

ផែនការមេរៀន និងការអនុវត្តផ្ទះបញ្ចាំង គុនិស្សិតនឹងទទួលបានឧបករណ៍ចាំបាច់សម្រាប់បង្រៀនភាសាខ្មែរនៅថ្នាក់បឋមសិក្សាឱ្យមានប្រសិទ្ធភាព ដើម្បីរៀបចំសិស្សឱ្យទទួលបានជោគជ័យក្នុងការសិក្សា។

*៤.៣.១.៤. ការវាយតម្លៃការសិក្សាភាសាខ្មែរកម្រិតបឋមសិក្សា [៣ (២-២-៥)]*

មុខវិជ្ជា "ការវាយតម្លៃការសិក្សាភាសាខ្មែរកម្រិតបឋមសិក្សា" មានគោលបំណងផ្តល់ឱ្យគុនិស្សិតនូវការយល់ដឹងស៊ីជម្រៅអំពីគោលការណ៍វាយតម្លៃ និងការអនុវត្តសម្រាប់វាយតម្លៃសមត្ថភាពទាំង៤ នៃភាសាខ្មែរក្នុងការអប់រំបឋមសិក្សា។ មុខវិជ្ជានេះគ្របដណ្តប់លើមូលដ្ឋានទ្រឹស្តីនៃការវាយតម្លៃ រួមទាំងការវាយតម្លៃដំណាក់ ការវាយតម្លៃសរុប ការវិនិច្ឆ័យតេស្ត និងការវាយតម្លៃផ្អែកលើការអនុវត្ត ដោយផ្តោតជាក់លាក់លើរបៀបដែលអាចអនុវត្តប្រកបដោយប្រសិទ្ធភាពនៅក្នុងថ្នាក់រៀនភាសាខ្មែរ។ គុនិស្សិត នឹងរៀនពីរបៀបរៀបចំ អនុវត្ត និងវិភាគការវាយតម្លៃដែលស្របតាមស្តង់ដាអប់រំសម្រាប់សិស្សបឋមសិក្សា ជាពិសេសតេស្តស្តង់ដាជាតិ និងតេស្តអន្តរជាតិ។ មុខវិជ្ជានេះក៏សង្កត់ធ្ងន់លើការបង្កើតការវាយតម្លៃដោយយុត្តិធម៌។ មុខវិជ្ជានេះក៏រួមបញ្ចូលនូវជំនាញសំខាន់ៗក្នុងការផ្តល់នូវមតិស្ថាបនា ដោយប្រើទិន្នន័យវាយតម្លៃដើម្បីកែលម្អយុទ្ធវិធីបង្រៀន និងធានាឱ្យស្របទៅនឹងស្តង់ដាកម្មវិធីសិក្សាជាតិ។ នៅចុងបញ្ចប់នៃមុខវិជ្ជាសិក្សា គុនិស្សិតអាចអនុវត្តឧបករណ៍វាយតម្លៃផ្សេងៗគ្នា ដើម្បីវាយតម្លៃជំនាញការអាន ការសរសេរ ការស្តាប់ និងការនិយាយរបស់សិស្សជាភាសាខ្មែរ និងគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពសិស្សជាបន្តបន្ទាប់ដែលអាចបន្សាំបានជាមួយការអនុវត្តតេស្តគ្រប់ប្រភេទគ្រប់ទម្រង់។

**៤.៣.២. គណិតវិទ្យា [១១ (៧-៨-១៨)]**

*៤.៣.២.១. ការបង្រៀន និងរៀនគណិតវិទ្យា I [៣ (២-២-៥)]*

មុខវិជ្ជានេះមានគោលបំណងឱ្យគុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋានគ្រឹះលើកញ្ចប់សម្ភារៈគណិតវិទ្យាថ្នាក់ដំបូងថ្នាក់ទី១ ទី២ និងទី៣ លើផ្នែកនព្វន្ត ពីជគណិត រង្វាស់រង្វាល់ ធរណីមាត្រនិងស្ថិតិ និងការវាយតម្លៃការសិក្សារបស់សិស្សនៅកម្រិតបឋមសិក្សា។ មុខវិជ្ជានេះត្រូវផ្តោតលើ ការសិក្សាកម្មវិធីសិក្សា ការរៀបចំផែនការបង្រៀន វិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀន សកម្មភាពបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ការផលិតសម្ភារៈបង្រៀន ការវាយតម្លៃការសិក្សារបស់សិស្ស និងហ្វឹកហ្វឺនគរុកោសល្យ។ ក្រោយបញ្ចប់មុខវិជ្ជានេះ គុនិស្សិតទទួលបានចំណេះដឹងលើវិធីសាស្ត្របង្រៀន និងអនុវត្តក្នុងការបង្រៀនគណិតវិទ្យាកម្រិតទាប (ថ្នាក់ទី១ ដល់ទី៣) ប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាព។

*៤.៣.២.២. ការបង្រៀន និងរៀនគណិតវិទ្យា II [៣ (២-២-៥)]*

មុខវិជ្ជានេះមានគោលបំណងឱ្យគុនិស្សិតទទួលបានចំណេះដឹងមូលដ្ឋានគ្រឹះលើ គណិតវិទ្យាថ្នាក់ដំបូងថ្នាក់ទី៤ ទី៥ និងទី៦ វិធីសាស្ត្រ (IBL 5Es, ProBL, PBL) និងវិធីបង្រៀន (រូបី ពាក់កណ្តាលរូបី ពាក់កណ្តាលអរូបី និងអរូបី អនុមានរួម និងអនុមានញែក) និងការវាយតម្លៃការសិក្សារបស់សិស្សនៅកម្រិតបឋមសិក្សា។ ចំណេះដឹងមូលដ្ឋានគ្រឹះដែលត្រូវសិក្សានៅក្នុងមុខវិជ្ជានេះផ្តោតលើខ្លឹមសារដូចជា ការបង្រៀនអំពីនព្វន្ត ពីជគណិត រង្វាស់រង្វាល់ ធរណីមាត្រ និងស្ថិតិ។ មុខវិជ្ជានេះផ្តោតលើ ការសិក្សាកម្មវិធីសិក្សា ការរៀបចំផែនការបង្រៀន វិធីសាស្ត្របង្រៀន យុទ្ធវិធីបង្រៀន សកម្មភាពបង្រៀន ការរៀបចំកិច្ចតែងការបង្រៀន ការផលិតសម្ភារៈបង្រៀន ការវាយតម្លៃការសិក្សារបស់សិស្ស និងហ្វឹកហ្វឺនគរុកោសល្យ។ ក្រោយបញ្ចប់មុខវិជ្ជានេះ គុនិស្សិតទទួលបានចំណេះដឹងលើវិធីសាស្ត្របង្រៀន និងអនុវត្តក្នុងការបង្រៀនគណិតវិទ្យាកម្រិតខ្ពស់ (ថ្នាក់ទី៤ ដល់ទី៦) ប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាព។

*៤.៣.២.៣. ការបង្រៀន និងរៀនគណិតវិទ្យា III [៣ (២-២-៥)]*

មុខវិជ្ជានេះមានគោលបំណងឱ្យគរុនិស្សិតទទួលបានចំណេះដឹងលើការដោះស្រាយលំហាត់គណិតវិទ្យា ដែលរួមមាន វិធីដោះស្រាយច្រើនរបៀប វិធីរកពហុចម្លើយត្រឹមត្រូវ ការគិតតាមបែបគណិតវិទ្យា និងហេតុផលគណិតវិទ្យា។ លើសពីនេះ មុខវិជ្ជានេះក៏ផ្តោតលើសមត្ថភាពគណិតវិទ្យា និងការវាយតម្លៃការសិក្សារបស់សិស្សនៅកម្រិតបឋមសិក្សាតាមរយៈរបាយការណ៍។ ចំណុចសំខាន់ៗដែលត្រូវយកចិត្តទុកដាក់លើការសិក្សាមុខវិជ្ជានេះគឺ ការសិក្សាកម្មវិធីសិក្សា ការបង្កើតលំហាត់ដែលមានវិធីដោះស្រាយច្រើនរបៀប មានពហុចម្លើយត្រឹមត្រូវ និងមានគ្រប់កម្រិតសមត្ថភាពគណិតវិទ្យា។ ក្រោយបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតទទួលបានចំណេះដឹងលើវិធីសាស្ត្រការបង្កើតលំហាត់គណិតវិទ្យាសម្បូរបែប ការវាយតម្លៃសមត្ថភាពសិស្ស និងអនុវត្តការបង្រៀនគណិតវិទ្យាប្រកបដោយទំនុកចិត្ត និងប្រសិទ្ធភាព។

*៤.៣.២.៤. ការវាយតម្លៃការសិក្សាគណិតវិទ្យានៅបឋមសិក្សា [២ (១-២-៣)]*

មុខវិជ្ជានេះមានគោលបំណងឱ្យគរុនិស្សិតទទួលបានចំណេះដឹងគ្រឹះលើការបង្កើតតេស្ត និងការវាយតម្លៃការសិក្សាគណិតវិទ្យានៅបឋមសិក្សា។ ចំណេះដឹងមូលដ្ឋានគ្រឹះដែលត្រូវសិក្សានៅក្នុងមុខវិជ្ជានេះផ្តោតលើខ្លឹមសារមួយចំនួនដូចជា ការរៀបចំផែនការនិងការបង្កើតតេស្ត ការវិភាគលទ្ធផលសិក្សារបស់សិស្សនិងសំណួរតេស្ត និងការកែលម្អសំណួរតេស្ត។ ការបង្កើតសំណួរតេស្តត្រូវមានលក្ខណៈស្តង់ដា ដែលបន្សីគ្នាជាមួយកម្មវិធីសិក្សាថ្នាក់ជាតិ ការវាយតម្លៃក្នុងតំបន់ (ឧ. SEA-PLM) និងការវាតម្លៃកម្រិតអន្តរជាតិ (ឧ. PISA) ជាដើម។ ក្រោយបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតទទួលបានចំណេះដឹង លើការរៀបចំផែនការនិងការបង្កើតតេស្ត ការវិភាគលទ្ធផលសិក្សារបស់សិស្ស និងសំណួរតេស្ត និងការកែលម្អសំណួរតេស្ត លើមុខវិជ្ជាគណិតវិទ្យាកម្រិតបឋមសិក្សា ដែលមានលក្ខណៈស្តង់ដា ដើម្បីអនុវត្តក្នុងការវាយតម្លៃ។

**៤.៣.៣. វិទ្យាសាស្ត្រ [៩ (៩-០-១៨)]**

*៤.៣.៣.១. ការសិក្សាកម្មវិធីសិក្សា និងការអនុវត្តវិទ្យាសាស្ត្រសម្រាប់បឋមសិក្សា [៣ (៣-០-៦)]*

មុខវិជ្ជានេះផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងអំពីការបង្កើតថ្មីក្នុងរចនាសម្ពន្ធកម្មវិធីសិក្សា និងការអនុវត្តសម្រាប់វិទ្យាសាស្ត្របឋមសិក្សា។ ខ្លឹមសារសំខាន់ៗដែលគរុនិស្សិតនឹងសិក្សាមានដូចជា ការសិក្សាពីមូលដ្ឋានគ្រឹះនៃមេរៀនវិទ្យាសាស្ត្រតាមបែបរិះរក ជ្រើសរើសខ្លឹមសារមេរៀនតាមការធ្វើផែនទីកម្មវិធីសិក្សា ការសិក្សាបញ្ញត្តិសម្ភារៈបង្រៀនសមស្រប ប្លង់ពិសោធន៍ ត្រៀមឧបករណ៍សង្កេត និងកត់ត្រា វិភាគកំណត់ត្រាសង្កេតថ្នាក់រៀន និងវាយតម្លៃដោយផ្តល់ព័ត៌មានត្រឡប់ប្រកបដោយតម្លាភាព គុណភាព និងប្រសិទ្ធភាពក្នុងការបង្រៀន និងរៀន។ លើសពីនេះទៅទៀត គរុនិស្សិតនឹងសិក្សាពីរបៀបបង្កើតសំណួរឱ្យបានត្រឹមត្រូវតាមកម្រិតទ្រឹស្តីប្លូមតាក់សូណូមីផងដែរ។ នៅពេលបញ្ចប់វគ្គសិក្សានេះ គរុនិស្សិតនឹងទទួលបានចំណេះដឹងជាមូលដ្ឋានទាក់ទងនឹងការសិក្សាកម្មវិធីសិក្សាមុខវិជ្ជាវិទ្យាសាស្ត្រនៅចំណេះទូទៅ ការអនុវត្តកម្មវិធីសិក្សា និងការរៀបចំអនុវត្តមេរៀនវិទ្យាសាស្ត្របឋមសិក្សា។

*៤.៣.៣.២. គរុកោសល្យសម្រាប់បឋមសិក្សា និងការវាយតម្លៃលើមុខវិជ្ជាវិទ្យាសាស្ត្របឋមសិក្សា [៣ (៣-០-៦)]*

មុខវិជ្ជានេះ ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការយល់ដឹងលើផ្នែកគរុកោសល្យសម្រាប់វិទ្យាសាស្ត្របឋមសិក្សា។ មុខវិជ្ជានេះផ្តោតលើប្រសិទ្ធភាពនៃការប្រើប្រាស់វិធីសាស្ត្រនៅក្នុងដំណើរការបង្រៀននិងរៀន និងវិធីសាស្ត្រសកម្ម

ក្នុងការលើកកម្ពស់ការលើកទឹកចិត្តសិស្ស ការរៀនសូត្រ ទទួលចំណេះដឹង និងការគិតបែបវិទ្យាសាស្ត្រ។ គរុនិស្សិតនឹងសិក្សាពីសារៈសំខាន់នៃការយល់ដឹងវិទ្យាសាស្ត្រ និងមូលដ្ឋានគ្រឹះសម្រាប់ការអប់រំបឋមសិក្សា។ មុខវិជ្ជានេះពន្យល់ពីបញ្ញត្តិគរុកោសល្យ ការសង្កេតមេរៀនវិទ្យាសាស្ត្រ (Naïve concept, constructivism, concept map, concept cartoon, context dependency, schema, science literacy, ethnography) ប្រសិទ្ធភាពក្នុងការគ្រប់គ្រងថ្នាក់រៀន (សម្ភារៈពិនិត្យវត្តមាន សម្ភារៈសុំជំនួយ សម្ភារៈវាយតម្លៃក្នុងការសិក្សា បណ្ណតួនាទី បណ្ណរូបភាព បណ្ណប្រមាណវិធី តុក្កតាគំនិត) វិធីសាស្ត្របង្រៀនបែបសកម្ម (វិធីបែបរិះរក /5Es, PBL, CBL) និងការអនុវត្តបង្រៀនសាកល្បងបញ្ញត្តិគរុកោសល្យណាមួយ ដោយប្រើប្រាស់វិធីសាស្ត្របង្រៀនសមស្របនឹងខ្លឹមសារមេរៀនក្នុងមុខវិជ្ជាវិទ្យាសាស្ត្របឋមសិក្សា។ ខ្លឹមសារសំខាន់ៗនៃមុខវិជ្ជានេះរួមបញ្ចូលការវាយតម្លៃការសិក្សាផងដែរ ដែលអាចឱ្យគរុនិស្សិតមានសមត្ថភាពក្នុងការរៀបចំតេស្តស្តង់ដា និងតេស្ត SEA-PLM យកទៅប្រើប្រាស់សម្រាប់ការបង្រៀន និងរៀននៅកម្រិតបឋមសិក្សា។ នៅពេលបញ្ចប់ការសិក្សា គរុនិស្សិតនឹងទទួលបានចំណេះដឹងមូលដ្ឋានពាក់ព័ន្ធនឹងការរៀបចំតេស្តវាយតម្លៃ និងបំណិនគរុកោសល្យសម្រាប់មេរៀនវិទ្យាសាស្ត្របឋមសិក្សា។

#### *៤.៣.៣.៣. នវានុវត្តន៍ក្នុងការរៀបចំ និងអនុវត្តគម្រោងសម្រាប់វិទ្យាសាស្ត្របឋមសិក្សា [៣ (៣-០-៦)]*

មុខវិជ្ជានេះផ្តល់នូវមូលដ្ឋានគ្រឹះ ដើម្បីស្វែងយល់អំពីការរៀបចំគម្រោងស្រាវជ្រាវ (ការច្នៃប្រឌិត) និងការអនុវត្តអង្កេតវិទ្យាសាស្ត្រសម្រាប់មុខវិជ្ជាវិទ្យាសាស្ត្របឋមសិក្សា។ ខ្លឹមសារសំខាន់ៗនៃការរៀបចំគម្រោងនឹងត្រូវពន្យល់ ព្រមទាំងរបៀបអនុវត្តនៅក្នុងការស្រាវជ្រាវឬអង្កេតតាមបែបវិទ្យាសាស្ត្រ។ វិធីសាស្ត្រស្រាវជ្រាវ នឹងត្រូវពិភាក្សាយ៉ាងយកចិត្តទុកដាក់។ នៅពេលបញ្ចប់មុខវិជ្ជាសិក្សានេះគរុនិស្សិតនឹងទទួលបាន ចំណេះដឹងមូលដ្ឋានទាក់ទងនឹងការរៀបចំគម្រោងស្រាវជ្រាវ និងវិធីរៀបចំគម្រោងឆ្លើយតបនឹងស្នែមដូចជា 7 Steps of STEM education Learning Approach និង Design Thinking Strategy និងការបង្កើតមេរៀននៅក្នុងមុខវិជ្ជាវិទ្យាសាស្ត្របឋមសិក្សា។

### ៤.៣.៤. សិក្សាសង្គម [១១ (៧-៨-១៨)]

#### *៤.៣.៤.១. ការបង្រៀន និងរៀនសិក្សាសង្គមនៅបឋមសិក្សា [៣ (២-២-៥)]*

មុខវិជ្ជានេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹង និងបំណិនជាមូលដ្ឋានលើការបង្រៀនសិក្សាសង្គមនៅកម្រិតបឋមសិក្សា។ ការសិក្សាមុខវិជ្ជានេះផ្តោតលើក្របខ័ណ្ឌកម្មវិធីសិក្សាកម្រិតបឋមសិក្សា កម្មវិធីសិក្សាលម្អិតកម្រិតបឋមសិក្សា សៀវភៅសិក្សាគោល វិធីសាស្ត្របង្រៀនសិក្សាសង្គម យុទ្ធវិធីបង្រៀន ការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន និងការផលិតសម្ភារឧបទេស។ មុខវិជ្ជានេះនឹងផ្តល់ចំណេះដឹង និងបំណិនច្បាស់លាស់ដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំឯកសារបង្រៀន និងការហ្វឹកហ្វឺនគរុកោសល្យតាមរយៈការងារបុគ្គល និងការងារក្រុម។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពប្រើប្រាស់កម្មវិធីសិក្សាលម្អិតកម្រិតបឋមសិក្សា រៀបចំការបង្រៀន និងអាចដឹកនាំសកម្មភាពបង្រៀន និងរៀនប្រកបដោយភាពបត់បែន និងមានប្រសិទ្ធភាព។

#### *៤.៣.៤.២. វិធីសាស្ត្របង្រៀន និងការវាយតម្លៃមុខវិជ្ជាសិក្សាសង្គមនៅបឋមសិក្សា [៣ (២-២-៥)]*

មុខវិជ្ជានេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹង និងបំណិនលើការបង្រៀន និងការវាយតម្លៃការសិក្សាលើមុខវិជ្ជាសិក្សាសង្គមនៅកម្រិតបឋមសិក្សា។ មុខវិជ្ជានេះផ្តោតលើការរៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន ការផលិតសម្ភារឧបទេស ការរៀបចំតេស្តស្តង់ដាសម្រាប់ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្សលើមុខវិជ្ជាសិក្សាសង្គម ស្របតាមលទ្ធផលសិក្សារំពឹងទុកក្នុងកម្មវិធីសិក្សាលម្អិត។ មុខវិជ្ជានេះ

នឹងផ្តល់ចំណេះដឹង និងបំណិនច្បាស់លាស់ដោយផ្សារភ្ជាប់ទ្រឹស្តីទៅនឹងការអនុវត្តជាក់ស្តែងលើការរៀបចំឯកសារបង្រៀន ការហ្វឹកហ្វឺនគរុកោសល្យ និងការរៀបចំការវាយតម្លៃការសិក្សាតាមរយៈការងារបុគ្គល និងក្រុម។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពរៀបចំនិងដឹកនាំការបង្រៀននិងរៀន និងការរៀបចំការវាយតម្លៃការសិក្សារបស់សិស្សប្រកបដោយភាពបត់បែន និងមានប្រសិទ្ធភាព។

### *៤.៣.៤.៣. បញ្ញត្តិ និងការអប់រំសិល្បៈ(គំនូរ-ហត្ថកម្ម) [២ (១-២-៣)]*

មុខវិជ្ជានេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹង និងជំនាញសិល្បៈមូលដ្ឋានផ្នែកគំនូរ និងហត្ថកម្ម សម្រាប់ប្រើក្នុងការរស់នៅប្រចាំថ្ងៃ ក៏ដូចជាការបង្រៀនសិល្បៈនៅកម្រិតបឋមសិក្សា។ មុខវិជ្ជានេះផ្តោតលើបញ្ញត្តិនៃសិល្បៈ គំនូរ សូនរូប និងកិច្ចការហត្ថកម្មនានាដែលផ្តល់គរុនិស្សិតនូវគំនិតជាមូលដ្ឋាននៃការរចនា ការផលិតសម្ភារៈនិងឧបករណ៍សិល្បៈ ព្រមទាំងសិប្បកម្មផងដែរ។ ការសិក្សានេះរួមបញ្ចូលទាំងការអប់រំខ្លឹមសារ ការអនុវត្តក្នុងអំឡុងពេលសិក្សាដោយមានជាកិច្ចការបុគ្គល កិច្ចការក្រុម ឬកិច្ចការគម្រោង និងការអប់រំវិធីសាស្ត្របង្រៀនសិល្បៈ(គំនូរ-ហត្ថកម្ម)នៅកម្រិតបឋមសិក្សាផងដែរ។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពមូលដ្ឋានក្នុងការគូរ បង្កើតស្នាដៃគំនូរ-ហត្ថកម្មសម្រាប់ពិព័រណ៍ និងរៀបចំការបង្រៀនសិល្បៈ(គំនូរ-ហត្ថកម្ម) នៅកម្រិតបឋមសិក្សាប្រកបដោយភាពច្នៃប្រឌិត។

### *៤.៣.៤.៤. បញ្ញត្តិ និងការអប់រំសិល្បៈ (តន្ត្រី-របាំ) [៣ (២-២-៥)]*

មុខវិជ្ជានេះមានគោលបំណងអភិវឌ្ឍសមត្ថភាពគរុនិស្សិតលើចំណេះដឹង និងជំនាញសិល្បៈមូលដ្ឋានផ្នែកតន្ត្រី និងរបាំ សម្រាប់ប្រើក្នុងការរស់នៅប្រចាំថ្ងៃ ក៏ដូចជាការបង្រៀនសិល្បៈនៅកម្រិតបឋមសិក្សា។ នៅក្នុងមុខវិជ្ជានេះ គរុនិស្សិតត្រូវសិក្សាមុខវិជ្ជាវងចំនួនពីររួមមាន តន្ត្រី និងរបាំ។ ផ្នែកតន្ត្រីផ្តោតលើបញ្ញត្តិនៃតន្ត្រី តន្ត្រីបុរាណ និងតន្ត្រីសម័យ និងការផ្សារភ្ជាប់ការអនុវត្តងាយៗក្នុងអំឡុងពេលសិក្សាដោយការប្រើឧបករណ៍ភ្លេងជាក់ស្តែង។ ផ្នែករបាំផ្តោតលើបញ្ញត្តិនៃរបាំ របាំក្បាច់បុរាណ របាំប្រពៃណី របាំប្រជាប្រិយ និងការផ្សារភ្ជាប់ការអនុវត្តក្នុងអំឡុងពេលសិក្សា។ ការសិក្សានេះ រួមបញ្ចូលទាំងការអប់រំវិធីសាស្ត្របង្រៀនសិល្បៈ(តន្ត្រី-របាំ) នៅកម្រិតបឋមសិក្សាផងដែរ។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានសមត្ថភាពមូលដ្ឋានក្នុងការច្រៀងចម្រៀងអប់រំ ការប្រគុំតន្ត្រីអប់រំ រាំរបាំ និងអាចដឹកនាំសកម្មភាពបង្រៀននិងរៀនតន្ត្រី និងរបាំនៅបឋមសិក្សាប្រកបដោយទំនុកចិត្ត។

## ៤.៣.៥. ភាសាបរទេស [៣ (២-២-៥)]

### *៤.៣.៥.១. វិធីសាស្ត្របង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា [៣ (២-២-៥)]*

មុខវិជ្ជានេះផ្តល់ឱ្យគរុនិស្សិតនូវចំណេះដឹងអំពី វិធីសាស្ត្របង្រៀនភាសាអង់គ្លេសកម្រិតបឋមសិក្សា។ មុខវិជ្ជានេះផ្តោតលើ ការបណ្តុះបណ្តាលគរុនិស្សិតឱ្យមានសមត្ថភាពក្នុងការបង្រៀនភាសាអង់គ្លេសលើជំនាញសំខាន់ៗដូចជា អំណាន ការស្តាប់ ការនិយាយ និងការសរសេរនៅកម្រិតបឋមសិក្សា។ លើសពីនេះទៀត មុខវិជ្ជាសិក្សានេះសង្កត់ធ្ងន់លើការរៀបចំកិច្ចតែងការបង្រៀន និងអនុវត្តការបង្រៀនភាសាអង់គ្លេសប្រកបដោយប្រសិទ្ធភាពនៅបឋមសិក្សា។ នៅពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតនឹងមានចំណេះដឹងលើវិធីសាស្ត្របង្រៀន និងបំណិនក្នុងការបង្រៀនភាសាអង់គ្លេសនៅបឋមសិក្សា ក៏ដូចជាអាចធ្វើការឆ្លុះបញ្ចាំង និងកែលម្អវិធីសាស្ត្របង្រៀនដើម្បីជួយសិស្សសម្រេចបានលទ្ធផលសិក្សារំពឹងទុក។

## ៤.៤. កម្មសិក្សាគរុកោសល្យ (២២ ក្រេឌីត)

កម្មសិក្សាគរុកោសល្យគ្របដណ្ដប់លើសមាសភាគនៃការសិក្សា ដែលត្រូវបានផ្សារភ្ជាប់ជាមួយសាលារៀន ដើម្បីទទួលបានបទពិសោធ និងការយល់ដឹងអំពីគ្រប់ទិដ្ឋភាពនៃការបង្រៀន។ តាមរយៈការអនុវត្តកម្មសិក្សាគរុកោសល្យ គរុនិស្សិតគ្រប់កម្រិតទាំងអស់នឹង ១) ទទួលបានបទពិសោធដំបូងនៃការបង្រៀន ២) អភិវឌ្ឍ និងអនុវត្តបំណិនបង្រៀនប្រតិបត្តិជាក់ស្ដែង (ការធ្វើកិច្ចតែងការបង្រៀន ការរៀបចំសកម្មភាព និងការគ្រប់គ្រងថ្នាក់រៀន) ៣) ស្រាវជ្រាវ និងស្វែងរកវិធីផ្សេងៗក្នុងការដោះស្រាយតម្រូវការសិស្ស និង ៤) ចូលរួម និងសិក្សាពីមិត្តរួមក្រុម និងអ្នកប្រឹក្សាគរុកោសល្យរួមទាំងគ្រូឧទ្ទេសដឹកនាំ និងគ្រូណែនាំដែលមានបទពិសោធ។ កម្មសិក្សាគរុកោសល្យមានគោលបំណងណែនាំគរុនិស្សិតអំពីបរិស្ថានសាលារៀន កសាងទំនុកចិត្តក្នុងថ្នាក់រៀន អភិវឌ្ឍសមត្ថភាពបង្រៀនក្នុងបរិបទផ្សេងៗគ្នា និងបង្កើតវិធីសាស្ត្រស្វ័យឆ្លុះបញ្ចាំងលើការបង្រៀននិងរៀន។ លើសពីនេះ កម្មសិក្សាគរុកោសល្យផ្ដល់ឱ្យគរុនិស្សិតនូវការយល់ដឹងកាន់តែទូលំទូលាយ ពីការគ្រប់គ្រងសាលារៀនទំនាក់ទំនងជាមួយសហគមន៍ និងការទទួលខុសត្រូវលើវិជ្ជាជីវៈរបស់ខ្លួន។

### ៤.៤.១. ការជកពិសោធននៅសាលារៀន (២ ក្រេឌីត)

ការអនុវត្តកម្មសិក្សាគរុកោសល្យឆ្នាំទី១ ស្ដីពី បទពិសោធនៅក្នុងសាលារៀន មានរយៈពេល ២សប្ដាហ៍។ កម្មសិក្សាគរុកោសល្យឆ្នាំទី១នេះ នឹងផ្ដល់ឱកាសដល់កម្មសិក្សាការី-ការិនី ក្នុងការសង្កេតដំណើរការបង្រៀននិងរៀនក្នុងថ្នាក់រៀនបឋមសិក្សា ដោយផ្អែកលើកម្រិតថ្នាក់ មុខវិជ្ជាឯកទេស និងធាតុផ្សេងៗទៀតនៃវិជ្ជាជីវៈបង្រៀន។ នៅកម្រិតបឋមសិក្សា ការអនុវត្តការសង្កេតការបង្រៀននឹងមានរយៈពេល ១សប្ដាហ៍នៅថ្នាក់រៀនកម្រិតទាប (ថ្នាក់ទី១ ដល់ទី៣) និង ១សប្ដាហ៍ទៀតនៅថ្នាក់រៀនកម្រិតខ្ពស់ (ថ្នាក់ទី ៤ដល់ទី ៦)។ ការធ្វើបែបនេះគឺដើម្បីផ្ដល់ឱកាសដល់កម្មសិក្សាការី-ការិនីបានសង្កេតបច្ចេកទេសបង្រៀននិងរៀន ឆ្លុះបញ្ចាំងរវាងទ្រឹស្ដីដែលបានរៀននិងការអនុវត្ត និងរបៀបគ្រប់គ្រងថ្នាក់រៀនជាដើម។ តាមរយៈការងារសង្កេត និងឆ្លុះបញ្ចាំងប្រចាំសប្ដាហ៍ កម្មសិក្សាការី-ការិនី នឹងមានឱកាសផ្សារភ្ជាប់រវាងទ្រឹស្ដីទៅនឹងការអនុវត្តជាក់ស្ដែងដោយសង្កេត កត់ចំណាំ ពិភាក្សាជាមួយមិត្តរួមក្រុម និងរៀនពីគ្រូបង្រៀន ហើយពួកគេក៏តម្រូវឱ្យត្រៀមខ្លួនសម្រាប់ឆ្នាំទី ២ និងបន្តទៅមុខទៀតផងដែរ។ នៅអំឡុងពេល២សប្ដាហ៍ នៃការអនុវត្តកម្មសិក្សាគរុកោសល្យឆ្នាំទី១ ស្ដីពីបទពិសោធក្នុងសាលារៀន កម្មសិក្សាការី-ការិនី នឹងសង្កេតដោយផ្ដោតលើតួនាទីនិងភារកិច្ចរបស់គ្រូបង្រៀន ការផ្សារភ្ជាប់ទ្រឹស្ដីនិងការអនុវត្តជាក់ស្ដែង ការគ្រប់គ្រងថ្នាក់រៀន ការរៀបចំសម្រាប់ការសន្ទនាឆ្លុះបញ្ចាំង និងរៀបចំផលបត្ររបស់ពួកគេសម្រាប់ការសង្កេតរយៈពេល ២សប្ដាហ៍។

### ៤.៤.២. ភាពជាអ្នកជំនួយការបង្រៀន (៥ ក្រេឌីត)

នៅឆ្នាំទី២ កម្មសិក្សាការី-ការិនី នឹងប្រើពេល ៥សប្ដាហ៍ជាជំនួយការបង្រៀននៅកម្រិតបឋមសិក្សាតាមការចាត់តាំងរបស់ក្រសួងអប់រំ យុវជន និងកីឡា។ នៅក្នុងអំឡុងពេល ៥សប្ដាហ៍នេះ កម្មសិក្សាការី-ការិនីនឹងសង្កេតការបង្រៀនរបស់គ្រូណែនាំ ចូលរួមនៅក្នុងការសន្ទនាឆ្លុះបញ្ចាំងប្រចាំសប្ដាហ៍ជាមួយគ្រូឧទ្ទេសដឹកនាំ រៀបចំសម្រាប់ការបង្រៀនផ្នែកណាមួយនៃមេរៀន ជួយរៀបចំកិច្ចតែងការបង្រៀន ជួយគ្រប់គ្រងធនធាន និងជួយគ្រប់គ្រងសិស្ស។ ក្នុងសប្ដាហ៍នីមួយៗ កម្មសិក្សាការី-ការិនី ត្រូវកត់ត្រាការសង្កេតនៅលើសន្លឹកកិច្ចការដើម្បីរៀបចំជាផលបត្រ។ ក្នុងភាពជាជំនួយការបង្រៀន កម្មសិក្សាការី-ការិនីនឹងទទួលបានបទពិសោធជាក់ស្ដែងតាមរយៈការជួយគ្រូណែនាំក្នុងការរៀបចំកិច្ចតែងការបង្រៀន ការផលិតសម្ភារឧបទេស ការគ្រប់គ្រងសិស្ស និងការជួយបង្រៀន

តាមផ្នែកផងដែរ។ កម្មសិក្សាការី-ការិនីកម្រិតបឋមសិក្សាឆ្នាំទី២ នឹងបន្តជាជំនួយការបង្រៀននៅកម្រិតថ្នាក់ដដែល នៅក្នុងរយៈពេល៥សប្តាហ៍ពេញដែលក្នុងនោះ ចំនួនពាក់កណ្តាលនៃក្រុមកម្មសិក្សាការី-ការិនី អាចនឹងអនុវត្តជំនួយការបង្រៀននៅក្នុងថ្នាក់រៀនកម្រិតទាប ហើយពាក់កណ្តាលទៀតនឹងអនុវត្តជំនួយការបង្រៀននៅក្នុងថ្នាក់រៀនកម្រិតខ្ពស់។ ប្រសិនបើពួកគេត្រូវបានចាត់តាំងឱ្យអនុវត្តជាជំនួយការបង្រៀននៅថ្នាក់បឋមសិក្សាកម្រិតខ្ពស់នៅក្នុងឆ្នាំទី២រួចហើយ លុះដល់នៅឆ្នាំទី៣ ពួកគេនឹងត្រូវអនុវត្តការបង្រៀននៅក្នុងថ្នាក់រៀនបឋមសិក្សាកម្រិតទាបវិញ និងយោងតាមការចាត់តាំងរបស់ក្រសួងអប់រំ យុវជន និងកីឡា។

### ៤.៤.៣. ការអនុវត្តការបង្រៀន ១ (៥ ក្រេឌីត)

ការអនុវត្តការបង្រៀន ១ ត្រូវបានអនុវត្តនៅឆ្នាំទី៣។ កម្មសិក្សាការី-ការិនីនឹងទទួលបានបទពិសោធក្នុងការអនុវត្តការបង្រៀននៅកម្រិតបឋមសិក្សា រយៈពេល៥សប្តាហ៍។ កម្មសិក្សាការី-ការិនីនឹងនៅតែបង្រៀនកម្រិតថ្នាក់ដដែលរយៈពេល ៥សប្តាហ៍ នៅថ្នាក់រៀនកម្រិតទាប ឬ កម្រិតខ្ពស់នៃសាលារៀនបឋមសិក្សា ដោយយោងតាមលិខិតឧទ្ទេសនាមរបស់ក្រសួងអប់រំ យុវជន និងកីឡា។ ប្រសិនបើ កម្មសិក្សាការី-ការិនីត្រូវបានចាត់តាំងឱ្យអនុវត្តកម្មសិក្សាគរុកោសល្យនៅថ្នាក់រៀនកម្រិតទាបក្នុងឆ្នាំទី២ នោះក្នុងឆ្នាំទី៣ពួកគេនឹងបង្រៀននៅថ្នាក់រៀនកម្រិតខ្ពស់វិញម្តង ក្នុងរយៈពេល ៥សប្តាហ៍ពេញដូចគ្នា។ ការអនុវត្តការបង្រៀន១ ផ្តល់ឱកាសដល់កម្មសិក្សាការី-ការិនី អនុវត្តផ្ទាល់នៅក្នុងស្ថានភាពជាក់ស្តែងរបស់សិស្ស និងទទួលបានបច្ចេកទេសផ្សេងៗក្នុងការបង្រៀន និងរៀន ដើម្បីពង្រឹងសមត្ថភាពរបស់ពួកគេឱ្យដល់កម្រិតខ្ពស់ (ដំណាក់កាលទី៣ នៃសមត្ថភាពអប់រំគរុនិស្សិតវិទ្យាស្ថានគរុកោសល្យ)។ កិច្ចការប្រចាំសប្តាហ៍នឹងជួយពួកគេឱ្យមានបំណិនក្នុងការរៀបចំផែនការបង្រៀន តែងការបង្រៀន សម្ភារឧបទេសដែលទាក់ទងនឹងខ្លឹមសារមេរៀន និងការបង្រៀនក្នុងថ្នាក់ដោយភាពឯករាជ្យម្ចាស់ការ។ អំឡុងពេលនេះ ពួកគេក៏នឹងយល់ស៊ីជម្រៅលើផ្នែកចំណេះដឹងនិងបំណិនក្នុងការបង្រៀននិងរៀន តាមរយៈការសង្កេតការបង្រៀនរបស់គ្រូណែនាំ ការបង្រៀនមេរៀនសាកល្បង ការបង្រៀនមេរៀនពេញលេញដោយឯករាជ្យ តាមរយៈការផ្តល់យោបល់កែលម្អរបស់មិត្តរួមក្រុម និងគ្រូឧទ្ទេសដឹកនាំនៅពេលប្រជុំឆ្លុះបញ្ចាំង។ ការអនុវត្ត កម្មសិក្សាគរុកោសល្យឆ្នាំទី៣នេះ ក៏ផ្តល់ឱកាសដល់កម្មសិក្សាការី-ការិនី សង្កេតពីបញ្ហាប្រឈមដែលពួកគេចាប់អារម្មណ៍ឱ្យបានកាន់តែលម្អិត ដើម្បីធ្វើការជ្រើសរើសប្រធានបទរួចសរសេរគម្រោងស្រាវជ្រាវរបស់ពួកគេនៅឆ្នាំទី៤ ក្នុងមុខវិជ្ជាស្រាវជ្រាវអប់រំ។

### ៤.៤.៤. ការអនុវត្តការបង្រៀន ២ (១០ ក្រេឌីត)

ការអនុវត្តការបង្រៀន ២ មានចំនួន១០ក្រេឌីត ហើយត្រូវអនុវត្តរយៈពេល១០សប្តាហ៍។ ក្នុងអំឡុងពេលនេះ កម្មសិក្សាការី-ការិនី នឹងបង្រៀនមេរៀនពេញលេញ រៀបចំផែនការបង្រៀន កិច្ចតែងការបង្រៀន រៀបចំធនធានសម្រាប់បង្រៀន គ្រប់គ្រងសិស្ស និងវាយតម្លៃការសិក្សារបស់សិស្ស។ កម្មសិក្សាការី-ការិនី ក៏នឹងជួយគ្រូណែនាំក្នុងការរៀបចំមេរៀន សម្ភារឧបទេសដែលស្របតាមខ្លឹមសារមេរៀន រៀបចំបរិស្ថានសិក្សាដែលគាំទ្រដល់ការសិក្សារបស់សិស្ស និងជួយដល់កិច្ចការផ្សេងៗទៀតទាំងក្នុងថ្នាក់ និងក្រៅថ្នាក់។ លើសពីនេះ កម្មសិក្សាការី-ការិនីនឹងធ្វើការងារលើសំណើស្រាវជ្រាវរបស់ពួកគេ ដោយប្រមូលទិន្នន័យសម្រាប់របាយការណ៍ស្រាវជ្រាវចុងក្រោយរបស់ពួកគេ។ ក្នុងអំឡុងពេល១០សប្តាហ៍នេះ កម្មសិក្សាការី-ការិនី ត្រូវរៀបចំពេលវេលាសម្រាប់ការសង្កេតថ្នាក់ជាផ្លូវការដោយគ្រូណែនាំយ៉ាងហោចណាស់ចំនួន៦ដង ដោយគ្រូឧទ្ទេសដឹកនាំយ៉ាងហោចណាស់ចំនួន ២ដង (ជាដំណាក់ ១មេរៀន និងសរុប ១មេរៀន) និងត្រូវចូលរួមប្រជុំសន្ទនាឆ្លុះបញ្ចាំងចំនួន ៣ដង (ការប្រជុំសន្ទនាឆ្លុះបញ្ចាំងលើកទី១ ធ្វើនៅសប្តាហ៍ទី១ ការប្រជុំសន្ទនាឆ្លុះបញ្ចាំងលើកទី២ ធ្វើនៅសប្តាហ៍ទី៥ និងការប្រជុំ

សន្ទនាឆ្លុះបញ្ចាំងលើកទី៣ ធ្វើនៅសប្តាហ៍ទី១០) ហើយរបាយការណ៍ឆ្លុះបញ្ចាំងក្នុងសប្តាហ៍នីមួយៗត្រូវបានសរសេរចូលទៅក្នុងទម្រង់របាយការណ៍សន្ទនាឆ្លុះបញ្ចាំងដើម្បីបញ្ចូលទៅក្នុងផលបត្រ។ តាមរយៈការអនុវត្តការបង្រៀនចំនួន ១០សប្តាហ៍ កម្មសិក្សាការី-ការិនី មានឱកាសអនុវត្តទ្រឹស្តីនិងគោលការណ៍នៃការបង្រៀននៅក្នុងថ្នាក់រៀន អភិវឌ្ឍការយល់ដឹងពីតួនាទីនិងភារកិច្ចសំខាន់ៗរបស់គ្រូបង្រៀន បង្កើនការយល់ដឹងពីសិស្ស (តម្រូវការរបៀបរៀន) ព្រមទាំងឆ្លើយតបឱ្យបានសមស្របទៅនឹងតម្រូវការ ផលប្រយោជន៍ និងសមត្ថភាពរបស់ពួកគេ។

## ៤.៥. ការស្រាវជ្រាវ (៦ ក្រេឌីត)

មុខវិជ្ជាការស្រាវជ្រាវ ផ្តល់ឱ្យគរុនិស្សិត នូវការប្រតិបត្តិវិជ្ជាជីវៈនៃការស្រាវជ្រាវ និងការពិនិត្យការអនុវត្តការបង្រៀន ជាប្រចាំនាំទៅរកការកែលម្អការបង្រៀននិងរៀនជាប្រចាំ។ មុខវិជ្ជានេះផ្តល់ជូនគរុនិស្សិតនូវគោលបំណង ដំណើរការ និងគុណតម្លៃនៃការស្រាវជ្រាវអប់រំនិងការស្រាវជ្រាវប្រតិបត្តិ នៅក្នុងបរិបទកម្រិតថ្នាក់រៀន។ លើសពីនេះទៀត មុខវិជ្ជានេះផ្តោតលើការអភិវឌ្ឍជំនាញក្នុង ការរៀបចំផែនការស្រាវជ្រាវ ការប្រមូលនិងវិភាគទិន្នន័យ ការបកស្រាយលទ្ធផល ការសរសេររបាយការណ៍ស្រាវជ្រាវ និងការធ្វើបទបង្ហាញលទ្ធផលរបាយការណ៍ស្រាវជ្រាវ។ មុខវិជ្ជានេះនឹងត្រៀមគរុនិស្សិតរួចជាស្រេចក្នុងការស្រាវជ្រាវប្រតិបត្តិដែលជាកាតព្វកិច្ចរបស់គរុនិស្សិតទាំងអស់ ដើម្បីបំពេញលក្ខខណ្ឌក្នុងការបញ្ចប់ការសិក្សា។

### ៤.៥.១. ការស្រាវជ្រាវអប់រំ [៣ (៣-០-៦)]

មុខវិជ្ជាស្រាវជ្រាវអប់រំ មានគោលបំណងផ្តល់ជូនគរុនិស្សិតនូវចំណេះដឹង និងជំនាញមូលដ្ឋានសម្រាប់ការស្រាវជ្រាវអប់រំ និងការស្រាវជ្រាវប្រតិបត្តិ ដូចជា ការជ្រើសរើសប្រធានបទ ការរៀបចំផែនការស្រាវជ្រាវ ការប្រមូលនិងវិភាគទិន្នន័យ ការបកស្រាយលទ្ធផល ការសរសេររបាយការណ៍ស្រាវជ្រាវ និងការបង្ហាញលទ្ធផលស្រាវជ្រាវ។ មុខវិជ្ជានេះក៏បានផ្តល់ឱ្យគរុនិស្សិត នូវបំណិនក្នុងការដកស្រង់ និងប្រើប្រាស់ឯកសារយោង ការសំយោគខ្លឹមសារ ក្រមសីលធម៌ក្នុងការស្រាវជ្រាវ និងជៀសវាងការលួចចម្លងស្នាដៃជាដើម។ ពេលបញ្ចប់មុខវិជ្ជានេះ គរុនិស្សិតមានចំណេះដឹង និងសមត្ថភាពក្នុងការសរសេរសំណើគម្រោងស្រាវជ្រាវប្រតិបត្តិ សម្រាប់ការត្រៀមអនុវត្ត និង/ឬប្រើប្រាស់ក្នុងការសរសេររបាយការណ៍បញ្ចប់ការសិក្សារបស់ពួកគេ។

### ៤.៥.២. គម្រោងស្រាវជ្រាវប្រតិបត្តិ (៣ ក្រេឌីត)

ការសរសេរគម្រោងស្រាវជ្រាវប្រតិបត្តិ មានគោលបំណងផ្តល់ជូនគរុនិស្សិតនូវឱកាសអនុវត្តការស្រាវជ្រាវនិងសរសេររបាយការណ៍ស្រាវជ្រាវជាក់ស្តែង ក្នុងអំឡុងពេលចុះកម្មសិក្សាគរុកោសល្យ។ លើសពីនេះទៅទៀត នៅក្នុងការសរសេររបាយការណ៍គម្រោងស្រាវជ្រាវប្រតិបត្តិនេះ ខ្លឹមសារ បញ្ញត្តិ ស្ថិតិ គណិតវិទ្យា ការវិភាគ ការបកស្រាយទិន្នន័យ និងទ្រឹស្តីនានាដែលពាក់ព័ន្ធនឹងការស្រាវជ្រាវអប់រំ នឹងត្រូវបានយកមកប្រើប្រាស់ដោយគរុនិស្សិតផ្ទាល់។ ក្រោយបញ្ចប់ការសរសេររបាយការណ៍ស្រាវជ្រាវប្រតិបត្តិ គរុនិស្សិត នឹងមានបំណិនការគិតកម្រិតខ្ពស់ បង្កើតស្នាដៃស្រាវជ្រាវថ្មី និងឆ្លុះបញ្ចាំងពីសមត្ថភាពសរសេររបស់ខ្លួន ដែលជាប្រយោជន៍ក្នុងអាជីពជាគ្រូបង្រៀន នៅថ្ងៃអនាគតរបស់ពួកគេ។

# ឯកសារយោង


ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) *ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀន មត្តេយ្យសិក្សា បឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ* នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២៣) *ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនឆ្នាំ២០២៤-២០៣០* នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២៥) *ផែនការយុទ្ធសាស្ត្រកែទម្រង់ការអប់រំគ្រូបង្រៀននៅកម្ពុជាឆ្នាំ២០២៤-២០៣០* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២៤) *ផែនការយុទ្ធសាស្ត្រវិស័យអប់រំឆ្នាំ២០២៤-២០២៨* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០២១) *ក្របខ័ណ្ឌកម្មវិធីអប់រំគ្រូបង្រៀនកម្រិតបរិញ្ញាបត្រអប់រំនៅវិទ្យាស្ថានគរុកោសល្យ* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១៦) *ក្របខ័ណ្ឌកម្មវិធីសិក្សាចំណេះទូទៅ និងអប់រំបច្ចេកទេស* នាយកដ្ឋានអភិវឌ្ឍកម្មវិធី ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *ស្តង់ដាគ្រឹះស្ថានអប់រំគ្រូបង្រៀន* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១៦) *កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅកម្រិតបឋមសិក្សា ១២+២* នាយកដ្ឋាន បណ្តុះបណ្តាលនិងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា (២០១១) *កម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិ* ១២+២ នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា(២០១០) *ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន* នាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា (២០០៤) *សេចក្តីសម្រេចប្រព័ន្ធក្រេឌីតនិង ការផ្ទេរក្រេឌីតនៅ កម្រិតឧត្តមសិក្សា លេខ០០៤/០៤គ.ទ.ក.សសរ* ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

Nanyang Technological University, National Institute of Education (2017). *Bachelor of Arts (Education) Bachelor of Science (Education)*, July 2017. NTU, NIE, Singapore.

Voskuilen, Wim. (2016). *Recommendations for developing a framework for a Bachelor of Education (B.Ed.)*, TTD/VSO, 2016. Phnom Penh.